សក្តញ្ជ សោ យាតិ សរីរភេទា ។

• ឱ. ម. ជាតេ ។

(៨២) (ស្តេចក្អែក...) អ្នកចំអកត្រាំនូវសេចក្តីស្រេកឃ្លាន ចាំងយប់ចាំងថ្ងៃ ដើរជាប់តាមខ្ញុំអស់ប្រាំពីរឆ្នាំហើយ កាលបើយ៉ាងនេះ ព្រោះហេតុអ្វីក៏អ្នកបង់ដោះខ្ញុំ ដែលកំពុងជាប់អន្ទាក់ឲ្យរួចអំពីអន្ទាក់វិញ ។ អ្នកទើបនឹងរៀរចាកបាណាតិបាតកង់ថ្ងៃនេះឬ ឬក៏អ្នកឲ្យអភ័យដល់សត្វចាំងពួង បានជាអ្នកបង់ដោះខ្ញុំ ដែលកំពុងជាប់អន្ទាក់ឲ្យរួចចាកអន្ទាក់វិញ ។

(៨៣) (កូនព្រានព្រៃ...) ម្នាលស្តេចក្អែក អ្នកចូរប្រាប់អំពីបុគ្គលដែលរៀរចាកបាណាតិបាតផង អ្នកដែលឲ្យនូវអភ័យដល់សត្វចាំងពួងផង ខ្ញុំសូមសួរអ្នកត្រង់សេចក្តីនុ៎ះ បុគ្គលនោះប្រុតអំពីលោកនេះទៅ នឹងបាននូវសេចក្តីសុខដូចម្តេចខ្លះ ។

(៨៤) (ស្តេចក្អែក...) ខ្ញុំនឹងប្រាប់អំពីបុគ្គល ដែលរៀរចាកបាណាតិបាតផង អ្នកដែលឲ្យនូវអភ័យ ដល់សត្វចាំងពួង បុគ្គលនោះរមែងបាននូវសេចក្តីសរសើរ កង់បច្ចុប្បន្នផង លុះបែកធ្លាយសរីរៈទៅ នឹងបានទៅកើតនៅឋានសួគ៌ផង ។

បកិណ្ណកនំបាតេ អដ្ឋមំ មហាមោរជាតកំ

(៩៥) ឧ សដ្ឋិ ឆេកា ឥតិ អាហុ ឃកេ
ឥឆេវ ជីវេ វិភវំ ឧបេតិ
តថា ឥលំ សុកតឧក្កជាតំ
ឧត្តុប្បញ្ញត្តភ្ញ វឧទ្ធិ ឆាឌំ
តេសំ វចោ អរហាតំ សុហាឆោ
តស្មា អហំ សក្កុណោ ឆាឆយាមិ ។

(៩៦) ចន្ទោ ច សុរិយោ ច ឧភោ សុឧស្សជា
តច្ឆន្តិ ទិភាសយមន្តលិក្ខេ
ឥមស្ស លោកស្ស បរស្ស ឯ តេ
កឥន្នុ តេ អាហុ មន្ទុស្សលោកេ ។

(៩៧) ចន្ទោ ច សុរិយោ ច ឧភោ សុឧស្សជា
តច្ឆន្តិ ទិភាសយមន្តលិក្ខេ
បរស្ស លោកស្ស ឧ តេ ឥមស្ស
ឆេឯតិ តេ អាហុ មន្ទុស្សលោកេ ។

(៨៥) (កូនព្រាន...) សមណព្រាហ្មណ៍ពួកខ្លះបាននិយាយថា ទេវតាទាំងឡាយ មិនមានទេ ដ៏ចំរើន កូនលោកនេះ រមែងដល់នូវសេចក្តីជាច់សូន្យ ផលនៃអំពើដែលសត្វធ្វើល្អ ធ្វើអាក្រក់ រមែងដល់នូវសេចក្តីជាច់សូន្យដូចគ្នា ទាំងនិយាយថាខានជាគុណជាតគឺមនុស្សល្ងង់បញ្ញត្តហើយ ខ្ញុំដឿងពាក្យ របស់សមណព្រាហ្មណ៍ ជាព្រះអរហន្តទាំងនោះ ហេតុនោះ បានជាខ្ញុំសម្លាប់សត្វស្មាបទាំងឡាយ ។

(៨៦) (ស្តេចកោក...) ព្រះចន្ទនិងព្រះអាទិត្យទាំងពីរ ជារបស់ឃើញងាយ ភ្លឺរុងរឿង នៅឰដ៏អាកាស ព្រះចន្ទនិងព្រះអាទិត្យទាំងនោះ (ជារបស់) លោកនេះឬលោកដទៃ (ពួកជន) ក្នុងមនុស្សលោកហៅព្រះចន្ទនិងព្រះអាទិត្យទាំងនោះថាជាអ្វី ។

(៨៧) (កូនព្រាន...) ព្រះចន្ទនិងព្រះអាទិត្យទាំងពីរ ជារបស់ឃើញងាយ ភ្លឺរុងរឿង នៅឰដ៏អាកាស ព្រះចន្ទនិងព្រះអាទិត្យទាំងនោះ (ជារបស់) លោកដទៃ មិនមែនរបស់លោកនេះទេ ពួកជន ក្នុងមនុស្សលោក ហៅព្រះចន្ទនិងព្រះអាទិត្យទាំងនោះថាជាទេវតា ។

(๙๘) ฝន្តេវ តេ ជីហតា ហីនភាគា
អហោតុកា យេ ន វន្ទន្តិ កម្ម៌
តថា ផលំ សុកតទុក្កដានំ
ធត្តុប្បញ្ញត្តំ យេ ច វន្ទន្តិ ធាតំ ។
(๙๙) អទ្ធា ហិ សច្ចំ វចនំ តវេតំ
កថញ្ហិ ធាតំ អផលំ ករេយ្យ
តថា ផលំ សុកតទុក្កដានំ
ធត្តុប្បញ្ញត្តញ្ច កថំ ករេយ្យ ។
កថញ្ហភេ កត្តិកភេ តត្ថមាចរំ
កឹ សេវមានោ តេន តថាតុលោន
អក្ខាហិ មេ (๑) មោរភរេតមត្តំ
យថា អហំ នោ ជិរយំ បតេយ្យំ ។
(๑๐๐) យេ កេចិ អត្ថិ សមណា បឋព្យា
តាសាយវត្តា អនតារិយំ ចរន្តិ
ថាតោវ បិណ្ឌាយ ចរន្តិ តាលេ
វិតាលចរិយា វិតតា ហិ សន្តោ ។

---

๑ ម. អក្ខាហិ តំ ភាតរំ មេ ។

(៩៨) (ស្តេចក្អែក...) សមណព្រាហ្មណ៍ណាមិនពោលអាងកម្ម មិនពោលអាងផលនៃកម្ម ដែលសត្វធ្វើល្អ ធ្វើអាក្រក់ មួយទៀត សមណព្រាហ្មណ៍ណា ពោលថា ទានជាគុណជាតដែលមនុស្សលង់បញ្ញត្តហើយ សមណព្រាហ្មណ៍ទាំងនោះ ជាអ្នកហីនវាទ ជាអ្នកអហេតុកវាទ ត្រូវគេដេញដើរទាល់តែងពាក្យវាណ៍នេះ មិនខាន ។

(៩៩) (កូនព្រានព្រៃ...) ពាក្យរបស់អ្នកនុ៎ះទៀងពិត ព្រោះទានជាគុណជាតឥតផលដូចម្តេចកើត ផលនៃអំពើដែលសត្វធ្វើល្អធ្វើអាក្រក់ក៏ដូចគ្នា ម្យ៉ាងទៀត (ទាន) ជាគុណជាតដែលមនុស្សលង់បញ្ញត្តហើយ ដូចម្តេចកើត ។ ខ្ញុំធ្វើអំពើដូចម្តេច ធ្វើដោយហេតុដូចម្តេច ប្រព្រឹត្តដូចម្តេច សេពនូវអ្វី ដោយគុណនៃតបៈដូចម្តេច មិនគប្បីធ្លាក់ទៅកាន់នរកយ៉ាងណា ម្នាលស្តេចក្អែក អ្នកសូមប្រាប់សេចក្តីនុ៎ះដល់ខ្ញុំ ដោយឧបាយយ៉ាងនោះ ។

(១០០) (ស្តេចក្អែក...) ពួកសមណៈណាមួយនៅលើផែនដី ជាអ្នកស្វែកសំពត់កាសាវៈ ប្រព្រឹត្តកន្លងនៃបុគ្គលគ្មានផ្ទះ ត្រាច់ទៅបិណ្ឌបាតអំពីព្រឹក កន្លងកាលគួរ រៀរចាកកិរិយាត្រាច់ទៅកន្លងកាលខុស ជាអ្នកសង្រួមរម្ងាប់ ។

បកំណ្ណកនិបាតេ អដ្ឋមំ បហាមោរជាតកំ

តេ តត្ថ ភារោ ទុប្បសង្គមិត្វា

បុត្តា មំ យំ តេ មនសោ បិយំ សិយា

តេ តំ បវក្ខន្តិ យថាបជានិំ

ឥមស្ស លោកស្ស បរស្ស ចត្តំ ។

(๑๐๑) តតោ ជិណ្ណោ ខុរតោ បុរាណោ

បណ្ដុបលាសំ ហរិតោ ទុមោវ

ឯសប្បមាទោ មម លុទ្ទភាវោ

ជហាមហំ[๑] លុទ្ទកភាវមជ្ជ ។

(๑๐๒) យេ ចាបិ មេ សកុណា អត្ថ ពន្ធា

សតាធិនេ ភោគាធិ ធនេសនេស្ស

តេសំ អហំ ជីវិតមជ្ជ ទត្វា

មោក្ខញ្ច តេ អច្ចសរិំ[๒] ធនេន ។

---

๑ ម. បដិហាមហំ ។ ម ជាមហំ ។ ๒ ម. បត្តា ។ បញ្ចត្តំ អដ្ឋកថាយំ ស្សត្ថំ ។

អ្នកចូរចូលទៅរកសមណៈទាំងនោះ តាមការសួរ ក្នុងទីនោះ ហើយ ចូរសាកសួរចុះ ប្រយោជន៍ណា ដែលទាក់ទងចិត្ត របស់អ្នក លោកនឹងទ្រាប់នូវប្រយោជន៍នោះ ជាប្រយោជន៍ កន្លងលោកនេះ នឹងកន្លងលោកខាងមុខ (ដល់អ្នក) តាមទំនង នៃការចេះដឹង (របស់លោក) ។

(១០១) (កូនព្រានព្រៃបានត្រាស់ជាព្រះបច្ចេកពុទ្ធហើយក៏សំដែង ថា) ភាពជាព្រានព្រៃនុ៎ះ អាត្មាអញបានលះបង់ហើយ អាត្មា អញបានលះបង់ នូវភាពនៃខ្លួនជាព្រានព្រៃក្នុងថ្ងៃនេះ ដូច ពស់សកនូវសំណកចាស់ជាន់មុន ឬក៏ដូចដើមឈើមានស្លឹក ខៀវ (ជម្រុះចោល) នូវស្លឹកលឿង ។

(១០២) (បច្ចេកពុទ្ធធ្វើសច្ចកិរិយាថា) ពួកបក្សីណាប្រើនរយ ដែល អាត្មាអញបានចងទុកក្បែរលំនៅ (របស់ខ្លួន) អាត្មាអញនឹង ឲ្យនូវជីវិតដល់សត្វទាំងឡាយនោះ ក្នុងថ្ងៃនេះ អាត្មាអញ បានរួចចាកកិលេសហើយ សត្វទាំងនោះ ចូរទៅកាន់ លំនៅរបស់ខ្លួនចុះ ។

สุตฺตนฺตปิฏกโต ขุทฺทกนิกายสฺส ชาตกโต

(๑๐๓) ลุทฺโธ จายํ ตาสมาคฺโค อรญฺ

ญาเณน เมวาภิยตึ ยสสฺสึ

ตณฺหา มหาภิยตึ ยสสฺสึ

ขุทฺทา ปมุญฺเจ ยถาหิ ปมุตฺโตติ ฯ

มหาหาโรชาตกํ อฏฺฐมํ ฯ

ตติยสฺสกชาตกํ

(๑๐๔) ยาเนสมาสาวิตวิมฺหา ปฺจาสาน วสาน ฉ

อเทฺวสีวิลเย ญาตี เตเม อนิกตา มยา ฯ

ตหิ จินฺติ มูลผลํ กตฺวา ตายี อนปฺปโก

รฏฺเ จิมา ตินฺนฉฺโท ชาสุกาสา ภวิสฺสติ ฯ

สเจหิ วสิสฺสามิ สห สเทฺวหิ ญาตีหิ

อปฺปาสฺสุกฺกา นิราสงฺกี อาสา เหสา อกุโตภยา ฯ

(๑๐๓) (អតិសម្ពុទ្ធគាថា) ព្រោនព្រៃហាខរន្ធាក់កន្ធំដែ ត្រាំដៅកន្ធំព្រៃ ដើម្បីចាក់នូវស្តេចក្អែក ដែលមានយស លុះចាក់នូវស្តេចក្អែក ដែលមានយសបានហើយ ក៏បានរួចចាកសេចក្តីទុក្ខ ដូចតថាគតដែលបានរួច (ចាកទុក្ខដោយសយម្ភូញ្ញាណ) ដូច្នោះដែរ ។

ចប់ មហាមោរជាតក ទី៨ ។

តច្ឆសូករជាតក

(๑๐๔) (ជ្រូកឈ្មោះតច្ឆកៈពោលថា) យើងគាលស្វែងរកពួកញាតិណា ដើរទៅកាន់កំនឹងព្រៃចាំងឡាយ យើងតាមស្វែងរកពួកញាតិដ៏ច្រើន ឯពួកញាតិចាំងនោះយើងបានជួបហើយ ។ មើមឈើនឹងផ្លែឈើនេះដ៏ច្រើនផង ភក្សាហារនេះច្រើនផង កំនឹងស្មៅចាំងនេះជាទីរីករាយផង ជាលំនៅដ៏សប្បាយ ។ យើងនឹងមិនមានសេចក្តីខ្វល់ខ្វាយ មិនមានសេចក្តីរង្កៀស មិនមានសេចក្តីសោក មិនមានភ័យអំពីណា នឹងនៅកន្លែងនេះឯង ជាមួយនឹងពួកញាតិចាំងអស់ ។

បកិណ្ណកវគ្គោ ទុតិយោ តច្ឆសូករជាតកំ

[๑๐๕] អញ្ញាសិំ លេឡិំ បវិយេសេ សត្ថុ ឱ ๙๘ ទិដ្ឋតំ

សោ តច្ឆ សូករេ ហន្ត្វ ๙ជាតក្ខា វំ វំ ។

[๑๐๖] កោ ធុម្ហាកំ ๙๘ សត្ថុ កោ ញាតីសុសមាគតោ

ធុប្បដិសេ បដិសេតំ តំមេ អក្ខាហិ បុច្ឆតោ។

[๑๐๗] ឧទ្ធុក្ករជី មិកជា ពលី ធាហាវុឱ មិគោ

សោ តច្ឆ សូករេ ហន្ត្វ ๙ជាតក្ខា វំ វំ ។

[๑๐๘] ន ឱ ធាហា[๑] ន ទិដ្ឋត្ថំ ពលំ ការយេសមោហាតំ

សត្ថូ សមក្ខា ហុត្វាន វសំ ការហាម ឯតកំ។

[๑๐๙] មាធយច្ឆំ កណ្ហាសុខំ ភវំ ការសសំ តច្ឆក

យោ មំ យុទ្ធេ ការលយេ[๒] តំ មំ បច្ចា មាជាមសេ។

---

๑ ន ឱ ភាហិតំ ទិដ្ឋត្ថតិ អដ្ឋកថាយំ ទិស្សតិ ។ បណ្ឌិតេហិ សមេតំ។

(១០៥) (ពួកជ្រូកឯទៀតពោលថា) ម្នាលតម្ពកៈ អ្នកចូរសូន្យវាកនូវជ្រូកទាំងនេះ ឯទៀតវិញចុះ (ដ្បិត) កូនទីនេះមានសត្រូវចំពោះពួកយើង សត្រូវនោះ តែងមកកូនទីនេះ ហើយសម្លាប់ជ្រូកទាំងឡាយ (សំដៅតែជ្រូកណា) ដែលឆាត់ៗ ។

(១០៦) (តម្ពកៈ...) សត្វណាជាសត្រូវនឹងពួកយើងកូនទីនេះ សត្វណាកំចាត់បង់នូវញាតិ កំពុងនៅជួបជុំគ្នា ដែលសត្រូវកំចាត់បង់បានដោយក្រ អ្នក ខ្ញុំសួរហើយ ចូរជ្រាបនូវហេតុនោះ ។

(១០៧) (ពួកជ្រូក...) ម្រឹគ (មួយ) ជាស្តេចនៃម្រឹគ មានក្រឡានៃសរីរៈខាងលើ មានកំលាំងកាយ មានបង្កឹមជាអាវុធ ម្នាលតម្ពកៈ ម្រឹគនោះ មកកូនទីនេះ ហើយសម្លាប់ជ្រូកទាំងឡាយ ដែលឆាត់ៗ ។

(១០៨) (តម្ពកៈ...) ខ្លាយទាំងឡាយរបស់ពួកយើង មិនមែនជាមិនមានទេ កំលាំងក៏ប្រជុំប្លុះកូនកាយ បើពួកយើងទាំងអស់ជាអ្នកព្រមព្រៀងគ្នា នឹងធ្វើខ្លាតែម្នាក់ឯងនោះ ឲ្យលុះអំណាចបាន ។

(១០៩) (ពួកជ្រូក...) ម្នាលតម្ពកៈ អ្នកពោលនូវពាក្យជាទីគាប់ចិត្ត គាប់ត្រចៀកណាស់ ដូច្នេះ ប្រសិនបើជ្រូកណា ពោលចោលគាកូនបំបាំង យើងនឹងសម្លាប់ជ្រូកនោះ កូនកាលដាវាងក្រោយ ។

[๑๑๐] ชาณาติ ชาตา วิเรโต ฉุสชฺช

อกยิ ฉุ เต สพฺภิเตสุ ธิฏฺฐิ

ชาหา ฉุ เต มิตฺตวิโย ฉ สนฺติ

โย สงฺคมตฺโต กมณาว ฌายิ ฯ

[๑๑๑] ฉ เม ชาหา ฉ วิชฺชนฺติ ฅลิ กาเย สเมหิตุ

ญาตี ฉ ธิสฺสา สมฺปนฺนา ฬิกเต

ตสฺมา ฉ ฌายามิ วนมฺหิ ฬิกเต ฯ

สมสฺสุธิ ยนฺติ ธิสาธิสิ[๑] ปุเร

กยนฺติ เล ณาตเวสิเต ปุชฺช

เตชาธิ สงฺคมฺม วสนฺติ ฬิกเต

เยตฺถนฺติ ขุปฺปสมาชฺช เต มยา ฯ

ปวิณาย กสมฺปนฺนา สมิตา ฬิกวาธิเต

เต มิ สมกฺข หิเสยฺยุ ตสฺมา เนสิ ฉ ปตฺเตยฺย ฯ

---

๑ ฉ. ม. ทิเสาทิสิ ฯ

(១១០) (កូដជដិល..) ម្នាលអ្នកមានព្យាយាមជាធំពួកម្រឹគ ក្នុងថ្ងៃនេះ អ្នកវៀរចាកបាណាតិបាតឬ ឬក៏អ្នកឲ្យអភ័យដល់ពួកសត្វទាំងអស់ ឬមួយអ្នកមិនមានចង្អឹម បានជាអ្នកទៅប្លួបនឹងហ្វូង(ជ្រូក) ហើយសញ្ជប់សញ្ជឹង ដូចជាសត្វកំព្រា ។

(១១១) (ខ្ញុ...) ខ្ញុំមិនមែនជាមិនមានចង្អឹមទេ កំឡាំងក៏ប្រជុំប្លុះក្នុងកាយ ខ្ញុំម្ចាស់ឯង បានឃើញពួកញាតិរបស់ជ្រូកព្រមព្រៀងគ្នា ក្នុងទីតែមួយ ហេតុនោះ បានជាសញ្ជប់សញ្ជឹងក្នុងព្រៃ ។

បានឮថា ក្នុងកាលមុន ជ្រូកទាំងឡាយនេះ តែងទៅកាន់ទិសតូចធំ លុះភ័យគ្រប់សង្កត់ហើយ ក៏ស្វែងរកទីជ្រកកោនផ្សេងៗគ្នា ឥឡូវនេះ ជ្រូកទាំងនោះបិតនៅក្នុងទីណា ដែលខ្ញុំគ្រប់សង្កត់បានដោយលំបាក ជ្រូកទាំងនោះក៏មកនៅប្លួបជុំជាមួយគ្នា (ក្នុងទីនោះ) ។

ជ្រូកទាំងឡាយនោះ បរិបូណ៌ដោយនាយក ប្រុងប្រៀបខ្លួនមូលមាត់គ្នា ព្រមព្រៀងគ្នា គប្បីបៀតបៀនទូវខ្ញុំ ព្រោះហេតុនោះ ខ្ញុំមិនប្រាថ្នាទូវជ្រូកទាំងនោះទេ ។

(๑๑๒) ฝเกาว ๙ฉ្ตา អសุเว ชิตาสิ

ฝเกาว เสเตา หาฐิ ธิเร ปสยฺห

ฝเกาว ฅฺยกฺขา มิตสงฺฆปเตฺต

ภำ ภำ หาฐิ ๓ลฌิ สาธิสำ ๆ

(๑๑๓) ธเหาว ๙ฉ្ตา ธเสเตา ธปิ ฅฺยกฺขา มิตาธิเหา

สมเตฺต สหิเต ญาตี ฅฺยกฺขา ธกฺขุเตวเส ๆ

(๑๑๔) กุกฺกิลกา สกุณิกา สงฺฆเหา ตณาหาริเหา

สพฺเพธมาสา ฝเกฆฺยำ ขุปฺปตฺถิ ขุยฺยฐิ ธ ๆ

เตสญฺ จิยมาสานำ ฝเกตฺต อปสกฺกติ

ตญฺเจ เสเตา ธิสาลเส วยฺยคฺฆิยาว สาตติ ๆ

(๑๑๕) ขุสฏฺฐมิเตา ๘ฉิลเธ ลุทฺเธสามิสธกฺขิสา

สาปิ สาปิสุ ปกฺขิฐิ ปญฺญาเตา ยถา ปุเร ๆ

(១១២) (កូដជដិល...) ព្រះឥន្ទ្រតែមួយអង្គ ឈ្នះនូវពួក អសុរៈ ខ្វែងតែមួយ សង្រ្គបធាបយកនូវពួកបក្សីបាន ខ្លាតែមួយ ចួបប្រទះនឹងម្រឹគក៏សម្លាប់នូវម្រឹគដែលធាត់ៗ បាន ដូ្រតថាកំលាំង (នៃខ្លានោះ) ប្រាកដដូ្រច្នោះ ។

(១១៣) (ខ្លា ..) មិនថាព្រះឥន្ទ្រ មិនថាខ្វែង មិនថាខ្លា ជាស្តេចនៃម្រឹគទេ ខ្លាមិនធ្លើ (នូវពួកដ្រុក) ដែលមានញាតិព្រមព្រៀងគ្នា ប្រុងប្រៀបខ្លួនទុក ឲ្យលុះកន្លងអំណាចបានឡើយ ។

(១១៤) (កូដជដិល..) ពួកបក្សីតូចៗ ឈ្មោះកុម្ភិលិកា មានហ្វូងហើរទៅ ទាំងហ្វូង រែកយករែកគ្នា ហើរទៅរែកចំណី ក៏ជាមួយគ្នា បានចំណីហើយ ហើរទៅ (តាមអាកាស) ក៏ជាមួយគ្នា ។ កាលបក្សីទាំងនោះ កំពុងមូលមិត្រគ្នា បណ្តាបក្សីទាំងនោះ គង់មានបក្សីមួយហើរឃ្លាតពីគេមិនខាន ខ្វែងធាបយកនូវបក្សីដែលហើរឃ្លាតពីគេនោះបាន នោះជាគតិរបស់ខ្លា ។

(១១៥) (អភិសម្ពុទ្ធគាថា) (ខ្លានោះ) ត្រូវដដិលអាត្រក់ ដែលមានក្អែកសំឡឹងតែអាមិសបញ្ឆោរហើយ អាងខ្លួនមានចង្កឹម ស្មានថាដូចមុន ក៏ស្ទុះទៅរកពួកដ្រុក ដែលមានខ្លាយដែរ ។

(១១៦) សាធុ សព្ពហុលា ញាតី អម្ហំ វុត្តា អវញ្ញា

សុភវេហេ សមក្កេហេ ឥក្ខ្វាកុយនេ ហោតោ។

(១១៧) ព្រាហ្មណាវោ ឥក្ខ្វាកុ ឧភោ ហត្ថាន សុភវ

អាធច្ចោ បមោធិតា មហាជាធមជាធិសុំ ។

(១១៨) តេសុធុម្មវមូលស្មឹ សុភវ សុសមាភតា

តច្ឆកំ អភិសំញ្ញុសុ ភុំជោ ភជាសំ ឥស្សរៃតំ។

តច្ឆសុករជាតកំ នវមំ ។

មហាវាណិជជាតកំ

(១១៩) ភាណិជា[1] សមិតិ ភត្វា ជានារដ្ឋតោ អាភតា

ជនហាភ បក្កមីសុ ឯកំ ភត្វាន តាមណឺ។

តេ តំ ភត្តារមាភម្ម អប្បភក្ខំ អន្ធនកំ

មហាធិក្រោធមន្ធក្ខុំ សីតច្ឆាយំ មនោរមំ ។

តេ ច តត្ថ ធិសីធិត្វា តិស្សរុក្ខស្ស ធាយា[2]

ភាណិជា សមចិន្តេសុំ ពាលា មោមោធ ចារុតា

អល្លាយតេ អយំ វុត្តោ អម្ហ ភារ សន្ធតំ

---

១ ម. សង្គតិ ។ ២ ម. ធាយាយ ។

(១១៦) (រុក្ខទេវតា...) គួរឲ្យសរសើរដែរ ពួកញាតិច្រើនរូប សូម្បីតែឈើដែលដុះក្នុងព្រៃ (ក៏គួរឲ្យសរសើរ) ខ្លា (ម្នាក់ឯង) ត្រូវពួកជ្រូកព្រមគ្នា សម្លាប់បានក្នុងផ្លូវតែមួយ ។

(១១៧) (អគិសមុទ្ទគាថា) ជ្រូកទាំងឡាយបានសម្លាប់នូវព្រាហ្មណ៍នឹងខ្លាធំទាំងពីរនាក់ហើយក៏ត្រេកអរពេកយ ស្រែកនូវសម្រែកដ៏ខ្លាំងៗ

(១១៨) ជ្រូកទាំងឡាយនោះ ប្រជុំគ្នាទៀបគល់នៃល្វា អគិសេកជ្រូកឈ្មោះតច្ឆកៈថា សូមព្រះអង្គជាស្តេចជាឥស្សរៈរបស់ពួកយើង ។

ចប់ តច្ឆសូករជាតក ទី ៩ ។

មហាវាណិជជាតក

(១១៩) (ព្រះសាស្តាទ្រង់ត្រាស់ថា) ពាណិជទាំងឡាយ ជាអ្នកស្វែងរកទ្រព្យមកអំពីដែនផ្សេងៗ ធ្វើនូវការប្រជុំ (ក្នុងក្រុងពារាណសី) ធ្វើបុគ្គលម្នាក់ ឲ្យជាធំ ហើយចៀសចេញទៅ ។ ពាណិជទាំងឡាយនោះ មកដល់ផ្លូវឆ្ងាយជាច់ស្រយាលនោះ ជាផ្លូវមិនមានស្បៀងអាហារមិនមានទឹក បានឃើញនូវដើមជ្រៃធំ មានមូលត្រជាក់ជាទីរីករាយនៃចិត្ត ។ ឯពាណិជទាំងនោះ ជាបុគ្គលល្ងង់ត្រូវមោហៈចិទ្ធាំងក៏អង្គុយក្រោមមូលឈើនោះ ក្នុងទីនោះ ហើយប្រឹក្សាគ្នាថា យីអើ ឈើនេះហាក់ដូចជាសើម ដោយទឹក ហាក់ដូចជាមានទឹកហូរទៅ

បដិណ្ណកមហាទេ ។ សមំ ធម្មាភិសមេតិ ឥតិ

ឥដ្ឋស្សុ បុរិមំ សាខំ យយំ ឆិជ្ជម ឥណាជា ។
សា ច ឆិជ្ជាវ បក្ខរិ អច្ឆំ ឥវ អនាវិលំ
តេ តត្ថ ភ្លាត្វា បិវិត្វា យោវតិច្ឆិសុ ឥណាជា
ទុតិយំ សមចិន្តេសុំ ពាលា មោហេន ឥវុតា
ឥដ្ឋស្សុ ឧត្តិណាំ សាខំ យយំ ឆិជ្ជម ឥណាជា ។
សា ច ឆិជ្ជាវ បក្ខរិ សាលិមំសោទនំ ពហុំ
អបេក្ខាទនវណ្ណោ ឥម្ហាសេ សប្បិផុលស្ស(១) បាយសោ
តេ តត្ថ ភុត្វា ខាទិត្វា យោវតិច្ឆិសុ ឥណាជា ។
តតិយំ សមចិន្តេសុំ ពាលា មោហេន ឥវុតា
ឥដ្ឋស្សុ បច្ឆិមំ សាខំ យយំ ឆិជ្ជម ឥណាជា ។
សា ច ឆិជ្ជាវ បក្ខរិ ឆារិយោ សមលង្កតា
វិចិត្តវត្ថាភរណា អាមុត្តមណិកុណ្ឌលា ។
អបិសុ ឥណាជា ឯកោ ឆារិយោ បញ្ចវីសតិ
សបត្តា បរិវារេសុំ តស្ស រុក្ខស្ស ឆាទិយា
តេ តាហិ បរិវារេត្វា យោវតិច្ឆិសុ ឥណាជា ។

---

១ ម. សិង្ឃិរេរំ លហុបិយោ ។

បើដូច្នោះ យើងជាពួកឈ្មួញនឹងកាប់នូវមែកឈើខាងកើត ។ សោតឯមែកនោះគ្រាន់តែត្រូវពួកឈ្មួញកាប់ជាប់ភ្លាម ក៏ស្រក់ទឹកចេញ ឯទឹកក៏ថ្លាមិនល្អក់ ពាណិជទាំងនោះបានឆ្លងផុតកន្លងទីនោះដរាបដល់អស់ចំណាយ ។ ពួកឈ្មួញពាល ត្រូវមោហៈបិទបាំង ប្រឹក្សានូវហេតុទី ២ ថា បើដូច្នោះ ពួកយើងជាពួកឈ្មួញ នឹងកាត់នូវមែកឈើខាងត្បូងនោះទៀត ។ សោតឯមែកឈើនោះ គ្រាន់តែត្រូវពួកឈ្មួញកាត់ជាប់ភ្លាម ក៏ហូរចេញនូវជ័រយៃនៃស្រវាសាលិ ដ៏លាយដោយសាច់ដ៏ច្រើន នូវនំកុម្មាស ហាក់ដូចជាជ័រយាសមានទឹកតិច នូវសម្លកកូរ នឹងសម្លសណ្តែកជ័រយ ពាណិជទាំងនោះ បានបរិភោគនំពាស៊ីកន្លងទីនោះដរាបតាល់អស់ចំណាយ ។ ពួកពាណិជល្ងង់ ដែលត្រូវមោហៈបិទបាំង ក៏ប្រឹក្សាគ្នានូវហេតុទី ៣ ថា បើដូច្នោះ យើងជាពួកឈ្មួញនឹងកាត់មែកឈើខាងលិចនោះទៀត ។ សោតឯមែកនោះគ្រាន់តែត្រូវពួកឈ្មួញកាត់ជាប់ភ្លាម ក៏ចេញនូវពួកនាគនារី មានខ្លួនតាក់តែងហើយ មានសំពត់នឹងគ្រឿងអាភរណៈដ៏វិចិត្រ ពាក់តែវមណីនឹងកុណ្ឌល ។ គួរសរសើរដែរ ពាណិជទាំងឡាយមាននាគនារីម្នាក់ៗ ចំណែកខាងនាគនារី ៤៥ នាក់ ចោមរោម (នូវនាយឈ្មួញជាធំ) ក្រោមម្លប់ឈើនោះដោយជុំវិញ ពាណិជទាំងនោះ ត្រូវនាគនារីទាំងនោះ ចោមរោមហើយ ដរាបអស់ចំណាយ ។

ចត្តុនំ សមចំឆ្តេសុំ ពាលា អោហេន ឆារុតា
ឥច្ឆស្ស ឧត្តរំ សាខំ មយំ ឆំឆាម វាណិជា ។
សា ច ឆំឆាវ បត្ថរំ មុត្តា វេឆ្បរិយា ពហូ
រជតំ ជាតរូបញ្ច កុត្តំយោ បដិយាឆំ ច
កាសិកាឆំ[1] ច វត្ថាឆំ ឧច្ចិយាឆំ ច កម្ពលា
តេ តត្ថ ភារេ ពន្ធិត្វា យាវតិច្ឆិសុ វាណិជា ។
បញ្ចមំ សមចំឆ្តេសុំ ពាលា អោហេន ឆារុតា
ឥច្ឆស្ស មូលេ ឆំឆាម អបិ កំយ្យោ លភាមសេ ។
អថុដ្ឋហិ សត្ថវាហោ យាចមានោ ភតញ្ចលំ
ឆំក្រោធោ កឹ អបរជ្ឈតិ វាណិជា ភទ្ទមត្ថុ តេ ។
វាវិធា បុរិមា សាខា អទ្ធចាឆញ្ច ឆក្កិណា
ជាវិធា បច្ឆិមា សាខា សព្ពភាមេ ច ឧត្តរា
ឆំក្រោធោ កឹ អបរជ្ឈតិ វាណិជា ភទ្ទមត្ថុ តេ ។

---

๑ ម. កាសំយោឆំ ។

ពួកពាណិជល្ងង់ ដែលត្រូវមោហៈបិទបាំង កំប្រឹក្សានូវហេតុ ទី ៨ ថា បើដូច្នោះ យើងជាពួកឈ្មួញ នឹងកាត់នូវមែកឈើខាងដើមនោះទៀត ។ សោតឯមែកនោះ គ្រាន់តែត្រូវពួកឈ្មួញកាត់ជាចំភ្លាម ក៏ហូរចេញនូវតែវមុក្តានឹងតែវពៃទូរ្យដ៏ច្រើនផង នូវប្រាក់ផង នូវមាសផង នូវកម្រាលសម្រាប់ក្រាលលើខ្នងដំរីជាដើមផង នូវកម្រាលរោមសត្វជាដើមផង នូវសំពត់ដែលគេធ្វើក្នុងដែនកាសីផង នូវសំពត់កម្ពលឈ្មោះទុទ្ធិយានៈផង ពាណិជទាំងនោះ ក៏វេចយកនូវភារៈដ៏ច្រើនលើសលប់ក្នុងទីនោះ ។ ពួកពាណិជល្ងង់ ដែលត្រូវមោហៈបិទបាំង កំប្រឹក្សានូវហេតុទី ៩ ថា បើដូច្នោះ ពួកយើងនឹងកាត់ត្រង់គល់ឈើនោះ មុខជានឹងបានច្រើនជាងនេះទៅទៀត គ្រានោះឈ្មួញជាធំ ក្រោកឡើងផ្គងអញ្ជលីអង្វរថា ដើមដ្រៃ ប្រទូស្តពួកអ្នកដូចម្តេច ម្នាលពាណិជទាំងឡាយ សេចក្តីចំរើនចូរមានដល់អ្នកចុះ ។ មែកខាងកើត បានឲ្យទឹកឆ្អឹតផង មែកខាងត្បូង បានឲ្យជ្រាយនឹងទឹកផង មែកខាងលិច បានឲ្យនាងនារីទាំងឡាយផង មែកខាងជើង បានឲ្យនូវសេចក្តីប្រាថ្នាគ្រប់យ៉ាងផង ដើមដ្រៃប្រទូស្តពួកអ្នកដូចម្តេច ម្នាលពាណិជទាំងឡាយ សេចក្តីចំរើនចូរមានដល់អ្នកចុះ ។

យស្សុក្ខសុនាយាយ និសីទេយ្យ សយេយ្យ វ,
ឆគស្ស សាខំ កញ្ចេយ្យ មិគទុព្ភោ ហិ ចាបលោ ។
តេ ច គស្ស អនាទិត្វា ឯកស្ស វចនំ ពហូ
និសិតាហិ កុហរីហិ មូលតោ នំ ឧបក្កមុំ ។
(๑๒๐)តតោ ជាតា និក្ខមិំសុ សន្ធេត្វា បញ្ចវីសតិ
ឆទ្ទុក្ខហានំ តិសតា ឆសហស្សា ច ចម្បិលោ ។
(๑๒๑) ឯតេ ហនថ ពន្ធថ មា ភេ មុញ្ចិត្ថ ជីវិតំ
ឃាបេត្វា សត្តកហំវ សព្ពេ កភេថ នេ ។
(๑๒๒) តស្មា ហិ បណ្ឌិតោ ភោគេ សម្បស្សំ អត្តមត្តនោ
ឈោកស្ស ន វសំ តច្ឆេ ហានេយ្យ និសតំ[๑] មនំ
ឃវមាធីនវំ ញត្វា តណ្ហា ទុក្ខស្ស សម្ភវំ
វីតតណ្ហោ អនាទានោ សតោ ភិក្ខុ បរិព្វជេតិ ។

មហាវាណិជជាតកំ ទសមំ ។

---

๑ ម. ហានេយ្យាវិសតំ ។

បុគ្គលរងើយឫផេក ក្រោមម្លប់នៃឈើណា មិនត្រូវគាប់បំបាក់មែកឈើនោះឡើយ ព្រោះថាបុគ្គលអ្នកប្រទូស្តមិត្រ ជាមនុស្សអាក្រក់។ ឯឈ្មួញទាំងនោះ ច្រើនគ្នា មិនអើពើនូវពាក្យនៃឈ្មួញជាធំម្នាក់ឯងនោះ ក៏ចូលទៅដើម្បីនឹងកាត់នូវដើមជ្រៃនោះត្រង់គល់ ដោយប៉ូវថៅទាំងឡាយ ដែលខ្លួនសំលៀងហើយ ។

(១២០) (អភិសម្ពុទ្ធគាថា) លំដាប់នោះ នាគទាំងឡាយ ២៥ សៀត គ្រឿងក្រោះហើយផង ពួកនាគខ្មាន់ធ្នូ ១០ផង ពួកទាហានកាន់ខែលក្រាំមួយពាន់ផង ក៏ចេញមក ។

(១២១) (នាគពួក...) អ្នកទាំងឡាយចូរសម្លាប់ ចូរចងនូវពាណិជទាំងនុ៎ះ អ្នកទាំងឡាយកុំលែងនូវដំរីតែឡើយ អ្នកទាំងឡាយ ចូរធ្វើនូវពួកពាណិជទាំងអស់នោះឲ្យទៅជាផែះ ទុកតែពាណិជជាធំម្នាក់ប៉ុណ្ណោះ ។

(១២២) (អភិសម្ពុទ្ធគាថា) ព្រោះហេតុនោះ បណ្ឌិតបុរស កាលបើបានឃើញច្បាស់ នូវប្រយោជន៍របស់ខ្លួន មិនគប្បីលុះអំណាចនៃលោភៈឡើយ ត្រូវតែកំចាត់បង់នូវចិត្ត ដែលប្រកបដោយលោភៈជ្រាលជ្រៅនោះ កិកីបើបានដឹងនូវទោស (ក្នុងលោភៈ) យ៉ាងនេះ ដឹងនូវការកើតឡើងនៃទុក្ខ ព្រោះតណ្ហា យ៉ាងនេះហើយ គប្បីប្រព្រឹត្តជាអ្នកមានតណ្ហាទៅប្រាសហើយ មិនមានសេចក្តីប្រកាន់មាំ មានស្មារតី ។

ចប់ មហាវាណិជជាតក ទី ១០ ។

សាធិនរាជជាតកំ

(១២៣) អត្ថតោ វតលោកស្មឹ ទុប្បដ្ឋេ លោមហំសនេ
ធិក្ករោថ ចាតុរហុ វេនេហ សរ្ជយសសរ្ជិនោ។
(១២៤) នេវបុត្តោ មហិទ្ធិកោ មាតលិ នេវសារថិ
ឯមន្តយិត្ថ ភជាឧំ វេនេហំ មិថិលគ្គហំ
ឯហិមំ រថមារុយ្ហ ភជ សេដ្ឋ ឯសមប្បតំ
នេក ឧស្សនតាមាតេ តារត្តឹសា សឥន្ទកា
សរមាណ ហិ តេ នេក សុធម្មាយំ សមច្ចរេ ។
តតោ ចភជា សាធិនោ វេនេហោ មិថិលគ្គហោ
សហស្សយុត្តំ អភិរុយ្ហ អគា នេកន សន្តិកេ
(សហស្សយុត្តំ ហយកហឹ ធិតូយានមធិដ្ឋតោ
យាយមានោ មហាភជា អទ្ទស នេវសកំ ឥធំ)
តំ នេក បដិនន្ទិសុ ធិស្វា ភជានមាគតំ
ស្វាគតន្តេ មហាភជ អថោ តេ អទុកគតំ
ឯសីនធានំ ភជិសំ នេវភជស្ស សន្តិកេ ។

សាធិនរាជជាតក

(๑๒๓) (ពួកអ្នកនគរពោលថា ស្តេចរបស់យើង) ចំឡែកណាស់តែ
គួរឲ្យព្រឺពេក កើតឡើង ក្នុងលោក រថជាទិព្យបានកើតប្រាកដ
ដល់ស្តេចវិទេហៈ ព្រះអង្គមានយស ។

(๑๒๔) (អភិសម្ពុទ្ធគាថា) ទេវបុត្រឈ្មោះមាតលី ជាទេវសារថី មានឫទ្ធិ
ច្រើន បានអញ្ជើញព្រះបាទវិទេហៈ ព្រះអង្គគ្រប់គ្រងក្រុងមិថិលាថា
បពិត្រព្រះពជាដ៏ប្រសើរ ជាម្ចាស់នៃទិស សូមព្រះអង្គយាងឡើង
កាន់រថនេះ ទេវតាទាំងឡាយជាន់តាវត្តឹង្សព្រមទាំងព្រះឥន្ទ្រ ចង់
ឃើញព្រះអង្គ ព្រោះទេវតាទាំងឡាយរលឹកព្រះអង្គ នៅរង់ចាំក្នុង
ពេលឈ្មោះសុធម្មា ។ លំដាប់នោះឯង ព្រះបាទវិទេហៈ ព្រះនាម
សាធិន ព្រះអង្គគ្រប់គ្រងក្រុងមិថិលា ទ្រង់យាងឡើងកាន់រថ ទឹម
ដោយសេះច្រើន ហើយបានយាងទៅកាន់សំណាក់នៃទេវតាទាំង
ឡាយ (ព្រះពជាជាធំ ទ្រង់ប្រថាប់លើទិព្វយានឈ្មោះហយវាហី
ដែលទឹមដោយសេះច្រើន កំពុងយាងទៅក៏បានទតឃើញទេវសភា
នេះ) ពួកទេវតាបានឃើញព្រះពជានោះមកដល់ហើយ ក៏ត្រេកអរ
ស្មោះចំពោះថា បពិត្រមហាពជ ព្រះអង្គយាងមកស្រួលហើយមិន
មែនយាងមកដោយមិនស្រួលទេ បពិត្រព្រះពជាអ្នកស្វែងរកគុណ
ដ៏ប្រសើរ ឥឡូវនេះសូមព្រះអង្គទ្រង់គង់ក្នុងសំណាក់នៃទេវពជចុះ ។

សព្ពាភិ បដិជគ្គន្តុ វេទេហិ មិថិលគ្គហិ
ឯវមត្តយេត្ថ ភោទេវិ អាសនេន ច ភាសវ
សាធុ ខោសិ អនុប្បត្តោ អាភតំ វសវត្តិនំ
វស ទេវសុ ភជិសំ សព្ពកាមសមិទ្ធិសុ
តាវត្តិំសេសុ ទេវេសុ កុញ្ជ ភាមេ អមាទុសេ ។

(๑๒๕) អហំ បុរេ សក្កតោ រមាមិ
ឆត្តេហិ ភីតេហិ ច ភទិតេហិ
សោធានំ អជ្ជ ន រមាមិ សក្កេ
អាយុក្ខ ខីណំ មរណន្តិ សន្តិកេ
ពុធាហុ មុច្ចិស្សំ ជនិន្ទសេដ្ឋ ។

(๑๒๖) ន តាយុ ខីណំ មរណាញ្ញ ទូរេ[1]
ន ចាបិ មុច្ចិ ន រីរសេដ្ឋ
តុយ្ហាញ្ញ បុញ្ញានិ បរិត្តភានំ
យេសំ វិបាកំ ឥធ វេទយិត្ថោ

---

๑ ម. ន ហាយុ ខីណំ មរណន្តេ ទូរេ ។ ម. នហាយុ ខីណំ មរណញ្ញ ទូរេ ។

ឯព្រះឥន្ទ្រក៏ទទួលពាក្យថ្លែងបំពោះព្រះបាទវិទេហៈ ព្រះអង្គគ្រប់គ្រងក្រុងមិថិលា ព្រះឥន្ទ្របានអញ្ជើញដោយគាមទាំងឡាយផង ដោយអាសនៈផងថា ប្រពៃណាស់ហើយ ព្រះអង្គបានដល់អាកាស របស់ទេវតាទាំងឡាយ ដែលញុំាងគេឲ្យប្រព្រឹត្តកន្លងអំណាចខ្លួន បពិត្រព្រះរាជាអ្នកស្វែងរកគុណដ៏ប្រសើរ សូមព្រះអង្គគង់នៅកន្លងពួកទេវតាដែលសម្រេចនូវកាមគ្រប់យ៉ាងបាន សូមព្រះអង្គសោយនូវកាមទាំងឡាយ ដែលមិនមែនជារបស់មនុស្សក្នុងពួកទេវតាជាន់តាវត្តឹង្សចុះ ។

(១២៥) (ព្រះបាទសាធិនរាជ...) កាលពីដើម ខ្ញុំមកនៅកន្លងមកក្នុងសួគ៌ តែកាយដោយរបាំចម្រៀងនឹងប្រគំទាំងឡាយ ឥឡូវនេះ កន្លងថ្ងៃនេះ ខ្ញុំមិនត្រេកអរកន្លងមកនៅសួគ៌ទេ បពិត្រព្រះជនិន្ទដ៏ប្រសើរ អាយុ (របស់ខ្ញុំ) នឹងអស់ឬ ឬសេចក្តីស្លាប់ (បិតនៅ) ក្នុងទីដិត ឬក៏ខ្ញុំជាបុគ្គលវង្វេង ។

(១២៦) (សក្កៈ...) បពិត្រព្រះអង្គដ៏ប្រសើរ មានពាក្យមួយជាងជនអាយុរបស់ព្រះអង្គមិនទាន់អស់ទេ ទាំងសេចក្តីស្លាប់របស់ព្រះអង្គ (ក៏បិតនៅ) ក្នុងទីឆ្ងាយ មួយវិញទៀត ព្រះអង្គ មិនមែនជាមនុស្សវង្វេងទេ តែថា ព្រះអង្គ សោយនូវផលនៃបុណ្យណា ក្នុងទេវលោកនេះ បុណ្យរបស់ព្រះអង្គនោះ តិច

វស ទេវានុភាវេន ភគវ សេដ្ឋ ធិសម្មតំ

តាវត្តិំសេសុ ទេវេសុ ភុញ្ជេ កាមេ អមានុសេ ។

(១២៧) យថា យាចិតកំ យានំ យថា យាចិតកំ ធនំ

ឯវំ សម្បទមេវេតំ យំ បរតោ ទានមិច្ឆយា

ន ចាហមេតមិច្ឆាមិ យំ បរតោ ទានមិច្ឆយា

សយំ កតានិ បុញ្ញានិ តំ មេ អាវេណិយំ ធនំ

សោហំ តត្ថាមនុស្សេសុ កាហាមិ កុសលំ ពហុំ

ទានេន សមចរិយាយ សំយមេន ទមេន ច

យំ កត្វា សុខិតោ ហោតិ ន ច បច្ឆានុតប្បតិ ។

(១២៨) ឥមានិ តានិ ខេត្តានិ ឥមំ ជនកំ សកុណ្ឌលំ

ឥមា តា បារិតានុភា ឥមា ធញ្ញា សវន្តិយោ

ឥមា តា ទោក្ខរណិយោ រម្មា ចាកាកុក្កុបកុដ្ឋិតា

បពិត្រព្រះករុណាជាធិប្រសើរ ជាម្ចាស់នៃទិស សូមព្រះអង្គគង់នៅដោយ
ទេវានុភាពចុះ សូមព្រះអង្គសោយនូវកាមទាំងឡាយ មិនមែន
ជារបស់មនុស្ស ក្នុងទេវលោកជាន់តាវត្តឹង្សចុះ ។

(១២៧) (ព្រះរាជា ..) យានដែលខ្លីគេ នឹងទ្រព្យដែលខ្លីគេ មានឧបមា
យ៉ាងណាមិញ ទ្រព្យណាដែលគេបាន ព្រោះបុគ្គលដទៃឲ្យជា
បច្ចុយ ទ្រព្យនុ៎ះឯង ក៏មានឧបមេយ្យយ៉ាងនោះដែរ ទ្រព្យណាដែល
គេបាន ព្រោះបុគ្គលដទៃឲ្យជាបច្ចុយ ខ្ញុំមិនចង់បានទ្រព្យនុ៎ះឡើយ
បុណ្យទាំងឡាយ ដែលខ្ញុំបានធ្វើហើយដោយខ្លួនឯង បុណ្យនោះទុក
ជាទ្រព្យរបស់ខ្ញុំជាប់តាមខ្លួន ខ្ញុំនោះនឹងទៅធ្វើកុសលឲ្យច្រើនក្នុងពួក
មនុស្ស ដោយឲ្យទានផង កិរិយាប្រព្រឹត្តិធម៌ស្មើផង កិរិយាសង្រួម
ដោយសីលផង កិរិយាទូន្មាននូវឥន្ទ្រិយផង ព្រោះថា បុគ្គលធ្វើ
កុសលហើយ រមែងដល់នូវសេចក្តីសុខ ទាំងមិនក្តៅក្រហាយ
រឿយៗ ក្នុងកាលជាខាងក្រោយ ។

(១២៨) (សាធិនរាជ ពោលនឹងស្តេចនារទៈថា) ស្រែទាំងឡាយនេះផង
ទឹកប្រកបដោយកុណ្ណលដ៏ល្អនេះផង ផែនដីដ៏ដេរដាស ដោយ
ស្មៅពណិខៀវនេះផង ស្តឹងទាំងឡាយដែលកំពុងហូរនេះផង ស្រះ
បោក្ខរណីទាំងឡាយ ជាទីរីករាយ មានសត្វចាកក្រពាកយំហើយ

---

១ ទឹកមានកំពែងសម្រាប់បុកទំលាយទឹកឲ្យហូរស្រួល ។ អដ្ឋកថា ។

បកិណ្ណកនិយាតេ ឯកាទសមំ សាធុនរាជធម្មកថំ

មណ្ឌាលតោ តេ សញ្ញា បឌុប្បលតោ ច
យស្សាមាធិ មមាយិ សុ តាធុ តេ សតំ តា ។

តាធិ ច ខេត្តាធិ សោ ភូមិកាតោ
តេយេវ អាភមវ្ហបថាក
តមេវ មយ្ហំ ជនតំ អបស្សតោ
សុញ្ញញ្ច មេ ជារធ ទាយតេ ធិសា ។

(១២៩) ធិដ្ឋា មយា វិមោធាធិ ឯកាសត្តា ចតុទ្ធិសា
សម្ភា នេវាជសត្ត តិធសាធញ្ច សម្ភា ។
វុត្តំ មេ ភវំ ធិព្យំ កុត្តា តាមា អមាធុសា
តាវត្តិសេសុ នេវេសុ សព្ភតាមសមិទ្ធិសុ ។
សោហំ ឝតាធិសំ ហិត្វា បុញ្ញាយម្ហិ ឥជាតតោ
ឆម្មេវ ចវិសព្ភាមិ ជាហំ រជ្ជេ អតិ្ឋតោ ។
អធណ្ហាវចរំ មក្ខំ សម្ភាសមុទ្ធនេសិតំ
តំ មក្ខំ បដិបជ្ជិស្សំ យេធ តច្ឆន្តិ សុព្ភតាតិ ។

សាធុនរាជធម្មកថំ ឯកាទសមំ ។

ដ៏ដេរជាសដោយចង្កូលណា ដោយផ្ការឈូក នឹងផ្កាឧប្បលនេះផង ពួកជនណា រាប់អានន្ទូវតីតំាងឡាយនេះថាជារបស់អញ ជនតំាងនោះ ទៅកាន់ទិសណាហ្ន៎ ។

ម្នាលនារទៈ ស្រែតំាងឡាយ នៅជាស្រែតំាងនោះដដែល ភូមិភាគ នៅជាភូមិភាគនោះដដែល ឧបចារៈនៃសួនច្បារតំាងឡាយ ក៏នៅជាឧបចារៈនោះដដែល តែថាកាលយើងមិនឃើញន្ទូវដនតំាងនោះ ទិសច្រាកដដល់យើង ហាក់ដូចជាសូន្យឈឹងៗ (១២៩)(ព្រះរាជា...)វិមានតំាងឡាយ ញុំាងទិសតំាង៨ឲ្យភ្លឺចំពោះមុខទេវរាជផង ចំពោះមុខពួកទេវតាជាន់ត្រៃត្រឹង្សផង យើងបានឃើញហើយ ។ តពាជាទិព្យយើងបាននៅរួចហើយ កាមតំាងឡាយមិនមែនជារបស់មនុស្ស យើងបានបរិភោគរួចហើយក្នុងពួកទេវតាជាន់តាវត្តឹង្ស អាចសម្រេចន្ទូវសេចក្តីប្រាថ្នាគ្រប់យ៉ាងបាន ។ យើងនោះបានលះបង់សម្បត្តិទិព្យច្រាកដដូច្នេះ ហើយមកកាន់ទីនេះ ដើម្បីធ្វើបុណ្យ យើងនឹងប្រព្រឹត្តធម៌តែម្យ៉ាង យើងមិនមានសេចក្តីត្រូវការដោយពាជសម្បត្តិទេ ។ ព្រះពុទ្ធតំាងឡាយដែលមានវត្តល្អ ស្តេចយាងទៅតាមផ្លូវណា យើងនឹងដើរទៅតាមផ្លូវនោះ ដែលព្រះសម្មាសម្ពុទ្ធសំដែងហើយ ជាផ្លូវដែលបុគ្គលមិនមានអាជ្ញាគប្បីត្រាច់ទៅ ។

ចប់ សាធិនរាជជាតក ទី ១១ ។

ទសព្រាហ្មណជាតកំ

(๑๓๐) រាជា អវោច វិទ្ធុរំ ឆម្មុគាមោ យុធិដ្ឋិលោ
ព្រាហ្មណោ វិទ្ធុរ បរិយេសរ សីលវន្ត ពហុស្សុតេ
វិរតេ មេថុនា ធម្មា យេ មេ ភុញ្ជេយ្យុ ភោជនំ
ទក្ខិណាំ សម្ម ទស្សាម យត្ថ ទិន្នំ មហាផលំ ។
(๑๓๑) ឧលូកា ព្រាហ្មណា នេវ សីលវន្ត ពហុស្សុតា
វិរតា មេថុនា ធម្មា យេ តេ ភុញ្ជេយ្យុ ភោជនំ ។
ទស ខលុ មហារាជ យា តា ព្រាហ្មណជាតិយោ
តាសំ វិភង្គវិចយំ វិត្ថារេន សុណោហិ មេ ។
បសិត្វកោ កហោត្ថាន បុណ្ណ មូលស្ស សំវុតោ
ជិលធិតាយេ កន្តន្តិ ភាបយន្តិ ជបន្តិ ច ។

ទសព្រាហ្មណជាតក

(១៣០) (ព្រះសាស្តាទ្រង់ត្រាស់ថា) ព្រះពជា ជាយុធដ្ឋិលគោត្រ ទ្រះអគ្គ្របុជ្ជាន្ទូវជមិ ជានត្រាស់នឹងអាមាត្យឈ្មោះវិធូរៈថា ម្នាលវិធូរៈ អ្នកចូរស្វែងរកនូវព្រាហ្មណ៍ទាំងឡាយ ដែលជាអ្នកមានសីល ជាពហុស្សូត្រ រៀរចាកមេថុនធម្ម ឲ្យមកបរិភោគនូវភោជនរបស់យើង ទក្ខិណាទានដែលគេឲ្យហើយចំពោះបុគ្គលណា ជាទានមានផលច្រើន ម្នាលសំឡាញ់ យើងនឹងឲ្យនូវទក្ខិណាទាន (ចំពោះបុគ្គលនោះ) ។

(១៣១) (អាមាត្យឈ្មោះវិធូរៈ ក្រាបទូលថា) បពិត្រព្រះសម្មតិទេព ពួកព្រាហ្មណ៍ដែលជាអ្នកមានសីល ជាពហុស្សូត្រ រៀរចាកមេថុនធម្ម គួរនឹងបរិភោគនូវភោជនរបស់ព្រះអង្គ គេរកបានដោយក្រ ។ បពិត្រមហាពជ ពួកថា ជាតិព្រាហ្មណ៍ទាំងឡាយណាមាន ១០ យ៉ាង សូមព្រះអង្គ ទ្រង់ព្រះសណ្តាប់ នូវការចែករំលែក នឹងការពិនិត្យពិច័យ នូវព្រាហ្មណ៍ទាំងនោះ តាមប្រជ្ញារបស់ទូលព្រះបង្គំជាខ្ញុំ ដោយពិស្តារចុះ ។ ព្រាហ្មណ៍ទាំងឡាយ កាន់ការពុំទាំងឡាយ ដែលពេញដោយឫសឈើ បងមាត់ជិត ហើយតែងក្សន ថ្នាំទាំងឡាយផង ផ្លូតទឹកឲ្យគេផង សែកនូវ(ភូតវិជ្ជា)ផង ។

តំ តេ ឥច្ចតិ សមา រាជ តេបិ ភុញ្ជន្តិ ព្រាហ្មណា

អក្ខាតា តេ មយា រាជ តាទិសេ ឯវ តាទិសេ ។

[๑๓๒] អបេតา តេ ច ព្រាហ្មណ្យา[๑] (ส่วนพระราชาตรัสว่า)

ន តេ ភុញ្ជន្តិ ព្រាហ្មណា

អញ្ញេ ហិ ធម្មា បរិយេសិ សីលវន្តេ ពហុស្សុតេ

ភិក្ខវេ មេត្តាវិហារិនោ យេ មេ ភុញ្ជេយ្យុ កោដិំ

ឧត្តរិំ សង្ឃឧទ្ទិសា យត្ថ ទិន្នំ មហប្ផលំ ។

[๑๓๓] តាទិំ ឯវ ឱភតោ ភាគេ យោ សេន្តិំ បុរតោ ឯតេ

បេសលានំ ឯវំ ភត្តន្តិ វេទវិយាសុ សិក្ខរេ ។

បរិហារិកេ សមា រាជ តេបិ ភុញ្ជន្តិ ព្រាហ្មណា

អក្ខាតា តេ មយា រាជ តាទិសេ ឯវ តាទិសេ ។

---

๑ ម. ព្រាហ្មណញ្ញា ។

បពិត្រព្រះពជា ឯព្រាហ្មណ៍ទាំងឡាយនោះ ស្មើដោយពេទ្យ គេ
ហៅថា ព្រាហ្មណ៍ដែរ បពិត្រមហាពជ (ព្រាហ្មណ៍ទាំងឡាយនេះ)
ទូលព្រះបង្គំជាខ្ញុំ បានក្រាបទូលចំពោះព្រះអង្គរួចហើយ យើងនឹង
ចូលទៅរកពួកព្រាហ្មណ៍ប្រាកដដូច្នោះឬ ។

(១៣២) (ព្រះពជាតោរព្យ:...)ពួកព្រាហ្មណ៍ទាំងនោះ ប្រាសចាកតាពជា
ព្រាហ្មណ៍ តែព្រាហ្មណ៍ទាំងនោះ គេមិនហៅថា ព្រាហ្មណ៍ទេ
ម្នាលវិធូរៈ អ្នកចូរស្វែងរកព្រាហ្មណ៍ទាំងឡាយដទៃវិញ ដែល
ជាអ្នកមានសីល ជាពហុស្សូត្រ រៀរចាកមេថុនធម្ម ឲ្យមកបរិភោគ
នូវភោជនរបស់យើង ម្នាលសំឡាញ់ ទក្ខិណាទាន ដែលគេឲ្យ
ហើយចំពោះបុគ្គលណា ជាទានមានផលច្រើន យើងនឹងឲ្យនូវ
ទក្ខិណាទាន (ចំពោះបុគ្គលនោះ) ។

(១៣៣) (វិធូរៈ...) ព្រាហ្មណ៍ទាំងឡាយនោះ កាន់យ៉ោះទាំងឡាយ
ហើយយោស្មាឮដ៏ខាងមុខ (នៃស្តេចនឹងអាមាត្យ) ក៏មាន ទៅកាន់ទី
សម្រាប់បម្រើគេក៏មាន សិក្សាខាងសិល្បវិទ្យាក៏មាន ។ បពិត្រព្រះ
ពជា ព្រាហ្មណ៍ទាំងឡាយនោះ ស្មើដោយជនអ្នកបំរើ គេហៅ
ថា ព្រាហ្មណ៍ដែរ បពិត្រមហាពជ (ព្រាហ្មណ៍ទាំងឡាយនេះ)
ខ្ញុំព្រះអង្គបានក្រាបទូលចំពោះព្រះអង្គហើយ យើងនឹងចូលទៅ
រកពួកព្រាហ្មណ៍បែបដូច្នោះឬ ។

(១៣៤) អបេតា តេ ច ព្រាហ្មញ្ញា (ឥតិ រាជា ច តោរព្យា)

ន តេ វុច្ចន្តិ ព្រាហ្មណា

អញ្ញេ វិប្ប បរិយេសស សីលវន្ត ពហុស្សុតេ

វីរតេ មេថុនា ធម្មា យេ មេ ភុញ្ជេយ្យុ កោដនំ

ឧក្កិលាំ សម្ម ឧសភ្ជាម យត្ត ឥដ្ឋំ មហាផលំ ។

(១៣៥) កាមណ្ហាលុំ តហោត្ថាន វច្ឆឧណ្ហាញ្ច ព្រាហ្មណា

បក្ខុបេស្សន្តិ រាជានោ តាមេសុ ឯតមេសុ ច

ឆានិន្នេ វុដ្ឋហោសភ្ជាម តាមម្ហិ ឯតមម្ហិ វា

ឯក្កាហតេសមា រាជ តេបិ វុច្ចន្តិ ព្រាហ្មណា

អក្ខាតា តេ មហារាជ តានិសេ ឯបតាមសេ ។

(១៣៦) អបេតា តេ ច ព្រាហ្មញ្ញា (ឥតិ រាជា ច តោរព្យា)

ន តេ វុច្ចន្តិ ព្រាហ្មណា

(១៣៤) (ព្រះរាជាកោរព្យៈ...) ព្រាហ្មណ៍ទាំងឡាយនោះប្រាសចាកភាពជាព្រាហ្មណ៍ តែព្រាហ្មណ៍ទាំងឡាយនោះ គេមិនហៅថាព្រាហ្មណ៍ទេ ម្នាលវិធុរៈ អ្នកចូរស្វែងរកនូវព្រាហ្មណ៍ទាំងឡាយដទៃវិញ ដែលជាអ្នកមានសីល ជាពហុស្សូត្រ រៀរចាកមេថុនធម្ម ឲ្យមកបរិភោគនូវភោជនរបស់យើង ម្នាលសំឡាញ់ ទក្ខិណាទានដែលគេឲ្យចំពោះបុគ្គលណា ជាទានមានផលច្រើន យើងនឹងឲ្យនូវទក្ខិណាទាន (ចំពោះបុគ្គលនោះ) ។

(១៣៥) (វិធុរៈ...) ព្រាហ្មណ៍ទាំងឡាយ កាន់ឃ្លោកជាក់ទឹកផង ដំបងកកផង ចូលទៅអែបអប នឹងស្តេចទាំងឡាយ ក្នុងស្រុកឫទិគម (ដោយគិតគ្នាថា) កាលបើគេមិនឲ្យ (វត្ថុអ្វីមួយ) ក្នុងស្រុក ឬនិគម យើងនឹងមិនក្រោកឡើយ បពិត្រព្រះរាជា ព្រាហ្មណ៍ទាំងឡាយនោះ ប្រាកដស្មើដោយបុគ្គលអ្នករឹបជាន់ គេហៅថាព្រាហ្មណ៍ដែរ បពិត្រមហាភាជ (ព្រាហ្មណ៍ទាំងឡាយនេះ) ខ្ញុំព្រះអង្គបានក្រាបបង្គំទូលចំពោះព្រះអង្គហើយ យើងនឹងចូលទៅរកពួកព្រាហ្មណ៍បែបដូច្នោះឬ ។

(១៣៦) (ព្រះរាជាកោរព្យៈ...) ព្រាហ្មណ៍ទាំងឡាយនោះប្រាសចាកភាពជាព្រាហ្មណ៍ តែព្រាហ្មណ៍ទាំងឡាយនោះ គេមិនហៅថាព្រាហ្មណ៍ទេ

បកិណ្ណកនិបាតេ ទ្វាទសមំ ទសព្រាហ្មណជាតកំ

អញ្ញេ វិទ្ធរ បរិយេសស សីលវន្ត ពហុស្សុតេ

វិវេតេ មេថុនា ធម្មា យេមេ កុញ្ជេយ្យ្រ គោធំ

ឧក្កំលាំ សម្ម ឧស្សាម យត្ថ និន្ទំ មហាបលំ ។

(๑๓๗) បរូឡ្ហកច្ចនខលោមា បន្ថ័ឧត្តា រជស្សិរ

ទិកិណ្ណា រជវេណ្ឌូហិ យាឧកា វិចរន្តិ តេ

ខាណុឃាតសមា ភាគ តេបិ វុច្ចន្តិ ព្រាហ្មណា

អក្ខាតា តេ មហាភាគ តាទិសេ និបតាមសេ ។

(๑๓๘) អបេតា តេ ច ព្រាហ្មញ្ញា (ឥតិ ភជា ច តោរព្យោ)

ឧ តេ វុច្ចន្តិ ព្រាហ្មណា

អញ្ញេ វិទ្ធរ បរិយេសស សីលវន្ត ពហុស្សុតេ

វិវេតេ ថ្មេមថ ធម្មា យេមេ កុញ្ជេយ្យ្រ គោធំ

ម្នាលវិធូរៈ អ្នកចូរសូន្មរកព្រាហ្មណ៍ចាំឆ្លាយដទៃវិញ ដែលជាអ្នកមានសីល ជាពហុស្សូត្រ រៀរចាកមេថុនធម្ម ឲ្យមកបរិភោគកោជនរបស់យើង ម្នាលសំឡាញ់ ទក្ខិណាទានដែលគេឲ្យហើយចំពោះបុគ្គលណា ជាទានមានផលច្រើន យើងនឹងឲ្យនូវទក្ខិណាទាន (ចំពោះបុគ្គលនោះ) ។

(១៣៧) (វិធូរៈ...) ព្រាហ្មណ៍ចាំឆ្លាយនោះ មានពោមក្រៀកនឹងក្រចកដុះវែង មានធ្មេញប្រកបដោយមន្ទិល មានធូលីលើក្បាល ពោយពាយដោយធូលីនឹងលំអងដី ត្រាច់ទៅសូម (ទ្រព្យផ្សេងៗ) បពិត្រព្រះរាជា ព្រាហ្មណ៍ចាំឆ្លាយនោះ ប្រាកដស្មើដោយជនអ្នកដកនូវដង្កត់ គេហៅថា ព្រាហ្មណ៍ដែរ បពិត្រមហារាជ (ព្រាហ្មណ៍ចាំឆ្លាយនេះ) ខ្ញុំព្រះអង្គបានក្រាបទូលចំពោះព្រះអង្គហើយ យើងនឹងចូលទៅរកព្រាហ្មណ៍បែបដូច្នោះឬ ។

(១៣៨) (ព្រះរាជាកោរព្យៈ...) ព្រាហ្មណ៍ចាំឆ្លាយនោះ ប្រាសចាកភាពជាព្រាហ្មណ៍ តែព្រាហ្មណ៍ចាំឆ្លាយនោះ គេមិនហៅថាព្រាហ្មណ៍ទេ ម្នាលវិធូរៈ អ្នកចូរសូន្មរកព្រាហ្មណ៍ចាំឆ្លាយដទៃវិញ ដែលជាអ្នកមានសីល ជាពហុស្សូត្រ រៀរចាកមេថុនធម្ម ឲ្យមកបរិភោគ នូវកោជនរបស់យើង

ឧក្កំសំ សព្ពទស្សាវិ យត្ថ និទ្ទំ មហាបលំ ។

(១៣៩) ហរីតកេសំ អាមលកេសំ អម្ពំ ជម្ពុំ វិភីតកេសំ

លគុឡំ ឧទ្ទាលកាឡាឡំ វេឡុកា ពទរាឡុ ច

ភជ្ជាយតនំ ខុទ្ទបូដិំ ឆមាយេត្ថំ មធុញ្ជហំ

ខុទ្ទាវាឡានិ បលាឡានិ[1] វិក្កីឡាន្តិ ជនាធិប

កណិជកាសមា ភជ្ជ តេបិ វុច្ចន្តិ ព្រាហ្មណា

អក្ខាតា តេ មហាភជ្ជ តាទិសេ និបតាមសេ ។

(១៤០) អវេតា តេ ច ព្រាហ្មញ្ញា (ឥតិ ភជ្ជា ច តោរព្យា

ឧ តេ វុច្ចន្តិ ព្រាហ្មណា

អញ្ញេ វិជ្ជរ បរិយេសរ សីលវន្ត ពហុស្សុតេ

វិវេកមេវុទា ឆម្មា យេ មេ អុញ្ជេយ្យ ភោជនំ

ឧក្កំសំ សព្ពទស្សាវិ យត្ថ និទ្ទំ មហាបលំ ។

---

១ ម. បណីតានំ ។

ម្នាលសំឡាញ់ ទក្ខិណាទាន ដែលគេឲ្យហើយចំពោះបុគ្គលណា ជាទានមានផលច្រើន យើងនឹងឲ្យនូវទក្ខិណាទាន (ចំពោះបុគ្គលនោះ)។

(๑๓๙) (វិធុរៈ...) បពិត្រព្រះជនាធិបតី (ព្រាហ្មណ៍ទាំងឡាយ) ដួញសម៉ងផង កន្ធូតត្រៃផង ស្ងោយផង ព្រីងផង សម៉ងពិកែផង ខ្ទះសម្ងូផង ឈើសួនផង ញែផង ពន្រាផង ឈើតែសផង ទឹកអំពៅនឹងស្ករអំពៅផង ខ្យៀផង ទឹកឃ្មុំនឹងថ្នាំបន្ដក់ក្អែកផង ដួញតណ្ឌៈមានតម្លៃតិចឬមានតម្លៃច្រើនផង បពិត្រព្រះរាជា ព្រាហ្មណ៍ទាំងឡាយនោះ ច្រូកដស្មៅដោយពាណិជ ហៅថា ព្រាហ្មណ៍ដែរ បពិត្រមហារាជ (ព្រាហ្មណ៍ទាំងឡាយនេះ) ខ្ញុំព្រះអង្គបានក្រាបទូលចំពោះព្រះអង្គហើយ យើងនឹងចូលទៅរកពួកព្រាហ្មណ៍បែបដូច្នោះឬ ។

(๑๔๐) (ព្រះរាជាកោរព្យៈ..) ព្រាហ្មណ៍ទាំងឡាយនោះ ច្រូកសចាកភាពជាព្រាហ្មណ៍ តែព្រាហ្មណ៍ទាំងឡាយនោះ គេមិនហៅថាព្រាហ្មណ៍ទេ ម្នាលវិធុរៈ អ្នកចូរស្វែងរកព្រាហ្មណ៍ទាំងឡាយដទៃវិញ ដែលជាអ្នកមានសីល ជាពហុស្សូត្រ រៀរចាកមេថុនធម្ម ឲ្យមកបរិភោគនូវភោជនរបស់យើង ម្នាលសំឡាញ់ ទក្ខិណាទានដែលគេឲ្យចំពោះបុគ្គលណា ជាទានមានផលច្រើន យើងនឹងឲ្យនូវទក្ខិណាទាន (ចំពោះបុគ្គលនោះ) ។

(๑๔๑) តេសំវលាំ ឆ្វំ តោរេត្វំ ចោសយត្វំ អនន្ធកេ
កុមារិយោ បវេច្ឆត្វំ វិភមាត្តាវមាត្វំ ច
សមា អត្តដ្ឋវេសេហិ តេមំ វុច្ចត្វំ ព្រាហ្មណា
អក្ខាតា តេមហាភាគ តាទិសេ ជំបតាមសេ។

(๑๔๒) អបេតា តេ ច ព្រាហ្មញ្ញា (ឥតិ ភជា ច តោរព្យោ)
ន តេវុច្ចត្វំ ព្រាហ្មណា
អញ្ញេ វិជ្ជរ បរិយេសរ សីលវន្តេ ពហុស្សុតេ
តំតេ មេជ្ជា ជម្មា យេ មេ កុញ្ជេយ្យុ កោជនំ
ឧក្កិលាំ សម្ម ឧស្សាម យត្ត ជិត្ថំ មហាបលំ។

(๑๔๓) ជិក្ខិត្តភិក្ខំ កុញ្ជត្វំ តាមេស្សេ តេ បុរេហិតា
ពហ្វ នេ បរិបុច្ឆត្វំ អណ្ណាច្ឆេធានំ លញ្ឆកា
បស្សមិ តត្ត មាញ្ជត្វំ មហឹសា សូករ អជា

(១៤១) (វិធូរៈ...)(ព្រាហ្មណ៍ចាំងឆ្កាយ) នាំគ្នាធ្វើនូវកសិកម្មនឹងពាណិជ្ជកម្មផង បញ្ចឹមពពែនឹងចៀមផង ទំនុកបម្រុងពួកកុមារីផង រៀបចំអាពាហ៍ពិពាហ៍ផង ព្រាហ្មណ៍ចាំងឆ្កាយនោះ ច្រើនដងស្មើដោយកុដុម្ពិកៈនឹងគហបតី គេហៅថា ព្រាហ្មណ៍ដែរ បពិត្រមហាពាជ (ព្រាហ្មណ៍ចាំងឆ្កាយនេះ) ខ្ញុំព្រះអង្គបានក្រាបទូលចំពោះព្រះអង្គហើយ យើងនឹងចូលទៅរកពួកព្រាហ្មណ៍បែបដូច្នោះឬ ។

(១៤២) (ព្រះពាជាកោរព្យៈ...) ព្រាហ្មណ៍ចាំងឆ្កាយនោះ ច្រើនដងភាពជាព្រាហ្មណ៍ តែព្រាហ្មណ៍ចាំងឆ្កាយនោះ គេមិនហៅថាព្រាហ្មណ៍ទេ ម្នាលវិធូរៈ អ្នកចូរស្វែងរកព្រាហ្មណ៍ចាំងឆ្កាយដទៃវិញ ដែលជាអ្នកមានសីល ជាពហុស្សូត្រ រៀរចាកមេថុនធម្ម ឲ្យមកបរិភោគនូវភោជនរបស់យើង ម្នាលសំឡាញ់ ទក្ខិណាទានដែលគេឲ្យចំពោះបុគ្គលណា ជាទានមានផលច្រើន យើងនឹងឲ្យនូវទក្ខិណាទាន (ចំពោះបុគ្គលនោះ) ។

(១៤៣) (វិធូរៈ...) មានព្រាហ្មណ៍ពួកខ្លះ ជាបុរោហិត (បរិភោគនូវកិក្ខាដែលគេទុកប៉ុន្មានឲ្យខ្លួន) ពួកជនច្រើនគ្នា តែងសាកសួរព្រាហ្មណ៍នោះ ព្រាហ្មណ៍ចាំងនោះជាអ្នកត្រៀវពង (គោជាដើម) ផង ជាគ្រូសាក់ផង សម្លាប់សត្វចិញ្ចឹមគឺក្របីជ្រូកនឹងពពែផង កន្ធផ្លុះនោះ

เตนายสฺมตา สมาโน สตฺถา โลกนฺตคู มุนิ
อกฺขาตา เตน มหาวีร ตาทิเสน นมตฺถุ เต ฯ

(๑๖๖) อเปตา เตน พฺราหฺมณา (สพฺเพ สมา ธ เตนาฬฺหา)

ธ เตนาฬฺหา พฺราหฺมณา
อญฺเญ วิชฺชาจรณูปปนฺนา สีลวนฺโต พหุสฺสุเต
วีรา เต เมถุนา ธมฺมา เยเมกญฺเญยฺยุ เกวลึ
ธมฺมิโล สงฺฆ ธมฺมญฺจ ยตฺถ ทินฺนา มหปฺผลา

(๑๖๗) อสิตฺวา ตโมนุทสฺส ขตฺติยา พฺราหฺมณา
เวสฺสา ปโยชเนสุ ทีฆรตฺตา สกฺกา อาราเธตุ นโร
สมา เตนาสิ เตนาเธหิ เตนาฬฺหา พฺราหฺมณา
อกฺขาตา เตน มหาวีร ตาทิเสน นมตฺถุ เต ฯ

បពិត្រព្រះរាជា ព្រាហ្មណ៍ទាំងឡាយនោះ ប្រាកដស្មើដោយបុគ្គលអ្នកសម្លាប់គោ គេហៅថាព្រាហ្មណ៍ដែរ បពិត្រមហារាជ (ព្រាហ្មណ៍ទាំងឡាយនេះ) ខ្ញុំព្រះអង្គបានក្រាបទូលចំពោះព្រះអង្គហើយ យើងនឹងចូលទៅរកព្រាហ្មណ៍បែបដូច្នោះឬ ។

(១៤៤) (ព្រះរាជាគោរព្យៈ...) ព្រាហ្មណ៍ទាំងឡាយនោះ ប្រាសចាកភាពជាព្រាហ្មណ៍ តែព្រាហ្មណ៍ទាំងឡាយនោះ គេមិនហៅថាព្រាហ្មណ៍ទេ ម្នាលវិធុរៈ អ្នកចូរស្វែងរកព្រាហ្មណ៍ទាំងឡាយដទៃវិញ ដែលជាអ្នកមានសីល ជាពហុស្សូត្រ រៀរចាត់មេបុនធម្មឲ្យមកបរិភោគនូវភោជនរបស់យើង ម្នាលសំឡាញ់ ទក្ខិណាទានដែលគេឲ្យចំពោះបុគ្គលណា ជាទានមានផលច្រើន យើងនឹងឲ្យនូវទក្ខិណាទាន (ចំពោះបុគ្គលនោះ) ។

(១៤៥) (វិធុរៈ...) ព្រាហ្មណ៍ទាំងឡាយកាន់ជាវនឹងខ្លែល កាន់ព្រះខាន់ឈរអែបនៅតែក្បែរផ្លូវ ជាទីទៅនៃពួកឈ្មួញ នាំពួកឈ្មួញឲ្យផុត (អំពីពួកចោរ) ព្រាហ្មណ៍ទាំងឡាយនោះ ប្រាកដស្មើដោយពួកជនអ្នកឃ្វាលគោនឹងពួកអ្នកនេសាទ គេហៅថា ព្រាហ្មណ៍ដែរ បពិត្រមហារាជ (ព្រាហ្មណ៍ទាំងឡាយនេះ) ខ្ញុំព្រះអង្គក្រាបទូលចំពោះព្រះអង្គហើយ យើងនឹងចូលទៅរកពួកព្រាហ្មណ៍បែបដូច្នោះឬ ។

(๑๒๖) អបេតា តេ ច ព្រាហ្មញ្ញា (ឥតិ រាជា ច តោរព្យោ)

ន តេ វុទ្ធិំ ព្រាហ្មណា

អញ្ញេ វិជ្ជរ បរិយេស សីលវន្តេ ពហុស្សុតេ

វិរតេ មេថុនា ធម្មា យេ មេ ភុញ្ជេយ្យុ ភោជនំ

ឧក្កំសំ សម្ម ធស្សាម យត្ត ទិន្នំ មហប្ផលំ ។

(๑๒๗) អញ្ញេ ភុដិកំ កត្វា ភុជានំ តាយន្តិ តេ

សសវិទ្ធរេ ពាធេន្តិ អាតោជា មច្ចកច្ចបំ

តេ លុទ្ធកសមា រាជ តេបិ វុទ្ធិំ ព្រាហ្មណា

អក្ខាតា តេ មហារាជ តាទិសេ ទិបតាមសេ ។

(๑๒๘) អបេតា តេ ច ព្រាហ្មញ្ញា (ឥតិ រាជា ច តោរព្យោ)

ន តេ វុទ្ធិំ ព្រាហ្មណា

អញ្ញេ វិជ្ជរ បរិយេស សីលវន្តេ ពហុស្សុតេ

វិរតេ មេថុនា ធម្មា យេ មេ ភុញ្ជេយ្យុ ភោជនំ

(១៤៦) (ព្រះពជាកោរព្យៈ...) ព្រាហ្មណ៍ទាំងឡាយនោះ ប្រាសចាកភាពជាព្រាហ្មណ៍ តែព្រាហ្មណ៍ទាំងឡាយនោះ គេមិនហៅថាព្រាហ្មណ៍ទេ ម្នាលវិធូរៈ អ្នកចូរស្វែងរកព្រាហ្មណ៍ទាំងឡាយដទៃវិញ ដែលជាអ្នកមានសីល ជាពហុស្សូត្រ រៀរចាកមេថុនធម្ម ឲ្យមកបរិភោគនូវភោជនរបស់យើង ម្នាលសំឡាញ់ ទក្ខិណាទាន ដែលគេឲ្យចំពោះបុគ្គលណា ជាទានមានផលច្រើន យើងនឹងឲ្យនូវទក្ខិណាទាន (ចំពោះបុគ្គលនោះ) ។

(១៤៧) (វិធូរ...) ព្រាហ្មណ៍ទាំងឡាយនោះ (ធ្វើខ្លួមក្នុងវៃ្រ ធ្វើអន្ទាក់វ័ធទាំងឡាយ បៀតបៀននូវទន្សាយនឹងភ្លុតត្រីផង នូវទន្សត្រីនឹងអណ្តើកផង បពិត្រព្រះពជា ព្រាហ្មណ៍ទាំងឡាយនោះប្រាកដស្មើដោយព្រានវៃ្រ ព្រាហ្មណ៍ទាំងនោះ គេហៅថា ព្រាហ្មណ៍ដែរ បពិត្រមហាពជ (ព្រាហ្មណ៍ទាំងនោះ) ខ្ញុំព្រះអង្គបានក្រាបទូលចំពោះព្រះអង្គហើយ យើងនឹងចូលទៅស្វែងរកព្រាហ្មណ៍បែបដូច្នោះឬ ។

(១៤៨) (ព្រះពជាកោរព្យៈ...) ព្រាហ្មណ៍ទាំងឡាយនោះ ប្រាសចាកភាពជាព្រាហ្មណ៍ តែព្រាហ្មណ៍ទាំងឡាយនោះ គេមិនហៅថា ព្រាហ្មណ៍ទេ ម្នាលវិធូរៈ អ្នកចូរស្វែងរកពួកព្រាហ្មណ៍ទាំងឡាយ ដទៃវិញ ដែលជាអ្នកមានសីល ជាពហុស្សូត្រ រៀរចាកមេថុនធម្ម ឲ្យមកបរិភោគនូវភោជនរបស់យើង

สุตฺตนฺตปิฏเก ขุทฺทกนิกายสฺส ชาตกํ

ธนญฺชโย สมฺม ธนสฺสาห ยตฺถ นิฏฺฐิ มหาปญฺโญ ฯ

(๑๔๙)อญฺเญ ธนสฺส การหาหิ เหฏฺฐา มญฺเญ ปสกฺขิตา

ราชาโน ขุปริ ภายนฺติ โสหมยาเค ขุปฏฺฐาเค

มลมชฺฌสหา ราช เตหิ ปุจฺฉิโต ปฺราหฺมณา

อกฺขาตา เต มหาราช ตาทิเส ฉินฺทตามเสฯ

(๑๕๐)อเถตา เต ธ ปฺราหฺมณา เส็ต ราชา ธ เการวฺยา)

ธ เต ปุจฺฉิโต ปฺราหฺมณา

อญฺเญ ปิงฺคฺย ปริเยส สีลวนฺโต พหุสฺสุเต

ปิโต เม เปตฺตโก ธมฺมา เยเม ภุญฺชยฺย เภาชนํ

ธนญฺชโย สมฺม ธนสฺสาห ยตฺถ นิฏฺฐิ มหาปญฺโญฯ

ម្នាលសំឡាញ់ ទក្ខិណាទានដែលគេឲ្យចំពោះបុគ្គលណា ជាទានមានផលច្រើន យើងនឹងឲ្យនូវទក្ខិណាទាន (ចំពោះបុគ្គលនោះ) ។

(១៤៩) (វិធូរៈ...) ព្រាហ្មណ៍ទាំងឡាយដទៃទៀត បានទ្រព្យ ក៏ដេកខាងក្រោមគ្រែ កាលសោមយាគ[1] ប្រាជ្ញកហើយ ស្តេចទាំងឡាយក៏ស្រង់ទឹកឮដ៏ខាងលើនៃគ្រែ បពិត្រព្រះរាជា ព្រាហ្មណ៍ទាំងឡាយនោះ ប្រាកដស្មើដោយជនអ្នកដុសក្អែល គេហៅថា ព្រាហ្មណ៍ដែរ បពិត្រមហារាជ (ព្រាហ្មណ៍ទាំងឡាយនេះ) ខ្ញុំព្រះអង្គបានក្រាបទូលចំពោះព្រះអង្គហើយ យើងចូលទៅរកពួកព្រាហ្មណ៍ប្រាកដដូច្នោះឬ ។

(១៥០) (ព្រះរាជាកោរព្យៈ...) ព្រាហ្មណ៍ទាំងឡាយនោះប្រាសចាកភាពជាព្រាហ្មណ៍ តែព្រាហ្មណ៍ទាំងឡាយនោះ គេមិនហៅថាព្រាហ្មណ៍ទេ ម្នាលវិធូរៈ អ្នកចូរស្វែងរកព្រាហ្មណ៍ទាំងឡាយ ដទៃវិញ ដែលជាអ្នកមានសីល ជាពហុស្សូត្រ រៀរចាកមេថុនធម្ម ឲ្យមកបរិភោគនូវភោជនរបស់យើង ម្នាលសំឡាញ់ ទក្ខិណាទានដែលគេឲ្យចំពោះបុគ្គលណា ជាទានមានផលច្រើន យើងនឹងឲ្យនូវទក្ខិណាទាន (ចំពោះបុគ្គលនោះ) ។

---

១ ការប្រជុំដោយទឹកសោម គឺសុរាមួយបែបដែលគេបានមកពីដើមឈើ និយមថាជាសុរាវិសេស សម្រាប់ឈែរក្នុងសែនព្រេន ។

បកិណ្ណកនិបាតេ សោសមំ ភិក្ខាបរម្បរជាតកំ

(១៥១)អត្ថំ ខោ ព្រាហ្មណា នេវ សីលវន្តោ ពហុស្សុតា

វិតា មេធុនោ ធម្មា យេ នេ ភុញ្ជេយ្យុ ភោជនំ។

ឯកញ្ច កតំ ភុញ្ជន្តិ ន ច មជ្ឈំ បិវន្តិ តេ

អក្ខាតា តេ មហារាជ តានិ សេ ឯបតាមសេ។

(១៥២)ឯតេ ខោ ព្រាហ្មណា វិញ្ញូ សីលវន្តោ ពហុស្សុតា

ឯតេ វិញ្ញូ បរិយេសេ ទិប្បញ្ច ឯនិមន្តយាតិ។

ទសព្រាហ្មណជាតកំ ទុតិយំ ។

ភិក្ខាបរម្បរជាតកំ

(១៥៣) សុខុមាលរូបំ ធិស្វា រដ្ឋា វិវនមាគតំ

ភូជាតារវូបេតំ មហាសយនមុត្តមំ[1]

តេសុ តេ បេមកោជាបំ អធាសិ វត្ថមោទនំ

សាលិំ វិចិត្តំ កត្តិ សុចិមំសូបសេចនំ

---

១ មហាសយនមុត្តមន្តិបិ ។

(១៥១) (វិទូរ ..) បពិត្រព្រះសម្មតិទេព ពួកព្រាហ្មណ៍ដែលជាអ្នកមានសីល ជាពហុស្សូត្រ រៀរាភក្នុងធម្ម គួរនឹងបរិភោគភោជនរបស់ព្រះអង្គ មានដែរ ។ ព្រាហ្មណ៍ទាំងនោះ បរិភោគនូវកត្តព្រៃតែម្តងទាំងមិនផឹកនូវទឹកស្រែវិង បពិត្រមហាពជ (ពួកព្រាហ្មណ៍នេះ) ខ្ញុំព្រះអង្គបានក្រាបទូលព្រះអង្គហើយ យើងនឹងចូលទៅអញ្ជើញពួកព្រាហ្មណ៍ច្រើនដូច្នោះឬ ។

(១៥២) (ព្រះពជា...) ម្នាលវិទូរៈ បើពួកព្រាហ្មណ៍ទុំៗឯង ជាអ្នកមានសីល ជាពហុស្សូត្រពិតមែន ម្នាលវិទូរៈ អ្នកចូរស្វែងរកពួកព្រាហ្មណ៍ទុំៗចុះ ចូរអញ្ជើញព្រាហ្មណ៍ទាំងនោះមកឆាប់ ។ ។

ចប់ ទសព្រាហ្មណជាតក ទី ១២ ។

ភិក្ខាបរម្បរជាតក

(១៥៣) (កុដុម្ពិកៈទូលថា) ខ្ញុំព្រះអង្គបានឃើញព្រះអង្គ មានព្រះរូបទន់ភ្លន់ចេញចាកដែនមកកាន់ព្រៃស្វាត់ ប្រកបដោយផ្នួងកំពូលដ៏ប្រសើរ មានអាសនៈដ៏ថ្លៃថ្លា ដែលគេក្រាលបំរុងទុក ទើបថ្វាយក្រយាស្មោយ ដ៏ឧត្តម ជាកត្តនៃស្រូវសាលី ដ៏វិចិត្រ លាយដោយសាច់ដ៏ស្អាត ចំពោះព្រះអង្គនោះ ដោយសេចក្តីស្រឡាញ់

តំ តុំ ភគ្គំ បដិក្កម្ម ព្រាហ្មណស្ស អធាបយិ
អត្តានំ អនសំតុាន តោយំ ឆម្ភេនមត្តតេ។

(๑๙๖)អាចរិយោ ព្រាហ្មណោ មយ្ហំ តិដ្ឋាតិ ច្ឆេសុ យ្វាវជោ
តវុ ច អាមន្តនំយោ ច ធាតុមរហាមិ តោជនំ ។

(๑๙๙)ព្រាហ្មណំ ធានំ បុច្ឆាមិ តោតមំ ភាវមូនិតំ
ភជា តេ ភគ្គំ ចាធាសិ សុចិមំសូបសេចនំ
តំ តុំ ភគ្គំ បដិក្កម្ម ឥសិស្ស តោជនំ អធា
អទ្ធញ្ញសិ ធានស្ស តោយំ ឆម្ភេនមត្តតេ។

(๑๙๖) ភភមិ បុត្តធារេ ច ឃរេសុ តជិតោ អហំ
តុញ្ញ អានុសតោ តោមេ អនុសាសាមិ ភជិតោ
អារញ្ញិតស្ស ឥសិតោ ចិរត្តំ តបស្សិតោ
វុឡ្ឍស្ស តាវិតត្តស្ស ធាតុមរហាមិ តោជនំ ។

ព្រះអង្គទទួលក្រយាស្មោយនោះហើយ តែមិនសោយដោយព្រះអង្គឯង ត្រឡប់ជាប្រទានដល់ព្រាហ្មណ៍វិញ សូមគ្រាបថ្វាយបង្គំចំពោះព្រះអង្គ តើការណ៍នេះជាសភាពដូចម្តេច ។

(១៥៤) (ព្រះពាជាត្រាស់ថា) ព្រាហ្មណ៍(នេះ) ជាអាចារ្យរបស់យើង ជាអ្នកឲ្យលាភ្វាយ ក្នុងកិច្ចតូចនឹងកិច្ចធំផង ជាបុគ្គលគួរគោរពផង គួរឲ្យយើងហៅរកផង (ព្រោះហេតុនោះ) យើងគួរឲ្យកោជន ។

(១៥៥) (កុដុម្ពិកៈ...) ឥឡូវនេះ ខ្ញុំសូមសួរព្រាហ្មណ៍ ជាគោតមគោត្ត ដែលស្តេចតែងបូជា ព្រះពាជាបានប្រទានកត្តដែលលាយដោយសាច់ដ៏ស្អាតដល់អ្នក អ្នកបានទទួលកត្តនោះហើយ ក៏បានប្រគេនឆ្អែតកោជនដល់ឥសីវិញ អ្នកប្រហែលជាដឹងថា ខ្លួនមិនមែនជាខេត្តនៃទាន ខ្ញុំសូមថ្វាយបង្គំចំពោះអ្នក តើការណ៍នេះជាសភាពដូចម្តេច ។

(១៥៦) (ព្រាហ្មណ៍តបថា) ខ្ញុំតែងចិញ្ចឹមកូននឹងប្រពន្ធផង ចំពាក់បិតុកង់ផ្ទះតាំងឡាយផង ប្រឹនប្រដៅព្រះពាជាថា សូមព្រះអង្គសោយនូវកាមតាំងឡាយ ជារបស់នៃមនុស្សផង ហេតុនោះបានជាខ្ញុំគួរប្រគេនកោជនដល់ឥសីវិញ ដែលនៅក្នុងព្រៃ មានតបៈអស់កាលវែង ចំរើនដោយគុណ មានចិត្តចំរើនហើយ ។

បកិណ្ណកនិយាតេ តេរសមំ ភិក្ខាបរម្បរជាតកំ

[១៥៧] ៥សំញ្ញានំ បុច្ឆាមិ តេសំ ធម្មំសុតំ
បរូឡ្ហកច្ចខលោមំ បង្កធម្មំ វនស្សរំ
ឯកោ អរញ្ញេ វិហរសិ ជាវកន្ទុសិ ជីវិតំ
តំក្ខុកោនុ នយោ សេយ្យោ យស្សុភ្ញំ កោធនំ អនា។

[១៥៨] ខលមាលុកលម្ពានំ តិលាលិតក្កលានំ ច
ជុនំ សាមាកនីវារំ សិហារិយំ បហារិយំ
សាកំ កិសំ មធុំ អិសំ ពទរាមលកានំ ច
តានំ អាហារ[1]កុញ្ញាមិ អត្តំ មេសោ បរិក្ខយោ
បច្ចន្តោ អបច្ចន្តស្សុ អមមស្សុ សកិញ្ចនោ
អនាធានស្សុ សាធានោ ធាតុមរហាមិ កោធនំ។

[១៥៩] តំក្ខុញ្ញានំ បុច្ឆាមិ តុណ្ហីមាសីន សុព្ភុតំ
តំតេ តេ ភត្តំ ចាធាសិ សុធំមំសូបសេចនំ
តំ ភុត្តំ បដិក្កុយ្ហ តុណ្ហី ភុញ្ជសិ ឯកកោ
ជាញ្ញំ តេ ភញ្ញំ មន្តេសិ កោយេ ធម្មោ ឧបត្តិតោ។

---

១ ម. អាភត្តា។ ម អាហរិត្តា។

(១៥៧) (កុដុម្ពិកៈ...) ឥឡូវនេះ ខ្ញុំសូមសួរឥសី ដែលស្គមរាំមរោម ដោយសរសៃ មានរោមក្រៀកនឹងក្របកដុះរែង មានឆ្នេញប្រកប ដោយមន្ទិល មានធ្មេញលើលក្បាល លោកនៅតែងព្រៃម្នាក់ឯង មិនស្តាយជីវិត លោកបានប្រគេនកោជនដល់កិកុណា កិកុនោះ ប្រសើរជាងលោក ដោយគុណដូចម្តេច ។

(១៥៨) (តាបសតបថា) អាត្មាដឹកដំឡូងឈ្មោះអាលុកលម្ពៈ នឹងតាលកន្ទៈ ទាំងឡាយផង ដំឡូងឈ្មោះពិលាលិ នឹងតក្កលៈទាំងឡាយផង ប្រុតស្រែងែនឹងស្ពៅ (យកមក) បែនបុក (បរិភោគ) ផង នាំយកគ្រឿងអន្ទក់នឹងក្រអៅឈូក ទឹកឃ្មុំ សាច់ ពពែនឹងកន្លួតព្រៃ មកបរិភោគផង នោះជាកំណាន់របស់អាត្មា អាត្មាជាបុគ្គលជាំស្ងួ មានសេចក្តីខ្វល់ខ្វាយ មានសេចក្តីប្រកាន់នៅឡើយ គួរប្រគេនកោជនដល់កិកុ ដែលជាអ្នកមិនជាំស្ងួ មិនមានតណ្ហា មិនមានសេចក្តីប្រកាន់ ។

(១៥៩) (កុដុម្ពិកៈ...)ឥឡូវនេះ ខ្ញុំសូមសួរកិកុ ដែលអង្គុយសៀមមានវត្តល្អដូចតទៅនេះ (ឥសី) បានប្រគេនកត្តដែលលាយដោយសាច់ដ៏ស្អាតដល់លោក លោកទទួលកត្តនោះហើយ ក៏បរិភោគសៀមៗម្នាក់ឯង មិនបានអញ្ជើញបុគ្គលដទៃណាមួយ (ឲ្យបរិភោគផង) ឡើយ ខ្ញុំសូមថ្វាយបង្គំចំពោះលោក តើការណ៍នេះជាសភាពដូចម្តេច ។

[๑๖๐] ន រថាមិ ន ភោគេមិ ន ឥច្ឆាមិ ន ឆេទនេ
តំ បំ វតាតិ្ជំ ញត្វា សព្វទាមេហិ អារតំ
ភាមេន តិក្ខមាទាយ ឧក្កិណោន ភមណ្ឌលុំ
ឥសិ មេ កត្តុំ ចាទាសិ សុចិមំសូបសេចនំ ។
ឯតេ ហិ ធាតុមរហន្តិ សមមា សបរិក្ខតោ
បច្ចនីកមហំ មញ្ញេ យោ ធាតារំ និមន្តយេ ។
[๑๖๑] អត្ថាយ វតាមេ អជ្ជ ឥធាគច្ឆ រជេសភោ
យោហំ អជ្ជ បជានាមិ យត្ថ ទិន្នំ មហប្ផលំ ។
រដ្ឋេសុ តិន្ទុ រាជានោ តិក្ខាតិក្ខេសុ ព្រាហ្មណា
ឥសី ឫសភលេ តិន្ទុ វិប្បមុត្តា ច តិក្ខវេតិ ។

កិក្ខាបរម្បរជាតកំ តេរសមំ ។

(១៦០) (ព្រះបាទកុរុ) អាត្មាមិនដាំស្មូនខ្លួនឯង មិនប្រើឲ្យគេដាំស្មូ
មិនកាត់ខ្លួនឯង មិនប្រើគេឲ្យកាត់ ហេតុនោះបានជាឥសីដឹងថា
អាត្មាជាអ្នកមិនមានសេចក្តីកង្វល់ ជាអ្នកប្រាសចាកបាបគ្រប់ចំពូក
ទើបកាន់ចង្ក្រានដោយដៃឆ្វេង កាន់សម្បកឃ្មោកដោយដៃស្តាំ ហើយ
ប្រគេនកត្តដែលលាយដោយសាច់ដ៏ស្អាតនោះដល់អាត្មា ។ តាម
ពិត ជនទាំងឡាយ(មានស្តេចជាដើម)នុ៎ះ ជាអ្នកប្រកាន់ថារបស់អញ
មានសេចក្តីហួងហែង គួរតែឲ្យទាន (ដល់បុគ្គលប្រាកដស្មើដោយ
អាត្មា) បុគ្គលណា អញ្ជើញនូវអ្នកឲ្យទាន (មកបរិភោគ) អាត្មា
សំគាល់ (នូវបុគ្គលនោះ) ថាជាអ្នកប្រតិបត្តិខុសទំនង ។

(១៦១) (កុដុម្ពិកៈ..) ក្នុងថ្ងៃនេះ ព្រះពជាព្រះអង្គប្រសើរលើរថ បាន
យាងមកកាន់ទីនេះ ដើម្បីប្រយោជន៍ដល់ខ្ញុំមែនហើយ ដ្បិតខ្ញុំបាន
ដឹងច្បាស់ក្នុងថ្ងៃនេះថា ទានដែលគេឲ្យហើយ ចំពោះបុគ្គលណា
ជាទានមានផលច្រើន ។ ស្តេចទាំងឡាយ ជាប់ចំពាក់ក្នុងដែនដី
ពួកព្រាហ្មណ៍ ជាប់ចំពាក់ក្នុងកិច្ចតូចនឹងកិច្ចធំ ពួកឥសី ជាប់ចំពាក់
ក្នុងមើមឈើ នឹងផ្លែឈើ ឯពួកកិក្ខុទើបរួចស្រឡះចាកកិលេស ។

ចប់ កិក្ខាបរម្បរជាតក ទី១៣ ។

បកិណ្ណកនិបាតស្ស ឧត្តមំ

តិសរុត្តមាលំ

សរូ តតិន្ទរមុក្កា ទារជិនសោ
តិសរជាត មហេសិ តកតោតវរោ
អថ មោរ សតច្ឆក ភលរិជតោ
អថ រាជ សព្រាហ្មណា តិក្ខបរំ ។

បកិណ្ណកនិបាតំ និដ្ឋិតំ ។

ឧទ្ទាននៃបកិណ្ណកនិបាតនោះគឺ

និយាយអំពីសេក ១ កិន្នរ ១ គប់ភ្លើង ១ ដំដែលដណ្តប់ស្បែកខ្លាឃ្មុំតាំងក្របក ១ ក្រអៅឈូក ១ អគ្គមហេសី ១ ព្រាបដ៏ប្រសើរ ១ ក្អែក ១ ជ្រូកឈ្មោះតច្ឆកៈ ១ ពាណិជ ១ សាធិនកជ ១ ព្រាហ្មណ៍ ១ ចង្ក្រានឲ្យតៗគ្នា ១ ។

ចប់ បកិណ្ណកនិបាត ។

វិសតិនិបាតជាតកំ

មាតង្គជាតកំ

(๑๖๒) ភុតោ ន អាកង្ខសិ ធុម្មកាសិ
ជិតស្វតោ បំសុបិសាចកោវ
សង្ការចោឡំ បដិមុញ្ច កណ្ឋេ
តោ វេតុវំ វោសិ អនក្ខណោយ្យោ ។
(๑๖๓) អន្ធំ តវយិំ បកតំ យសស្សិនំ[1]
តំ ទជ្ជវេ ភុញ្ជវេ បិយ្យវេ ច
ជានាសិ មំ តុំ បរទត្តូបជីវឺ
ឧត្តិដ្ឋបិណ្ឌំ លភតំ សចាតោ ។
(๑๖๔) អន្ធំ មមយិំ បកតំ ព្រាហ្មណានំ
អត្តត្ថាយ សន្ធហាតោ មមយិំ
អបេហិ ឯត្តោ តវមិច្ឆដ្ឋោសិ
ន ហាធិសា តុយ្ហំ ទទន្តិ ជម្ម ។

---

๑ ឯ. ម. យសស្សឺ ។

វិសតិនិបាតជាតក

មាតង្គជាតក

(១៦២) (មណ្ឌព្យកុមារសួរថា) អ្នកមកអំពីទីណា បានជាមានប្រជាប់ស្លៀកពាក់អាក្រក់ លាមក ដូចជាបិសាចលើអាចម៍ដីពាក់នូវកំណាត់សំពត់ ដែលគេចោលលើគំនរសម្រាមឮដ៏កន្ធត់អ្នកជាបុគ្គលផ្តេសផ្តាស មិនមែនជាទក្ខិណេយ្យបុគ្គលទេ ។

(១៦៣) (មាតង្គមហាសត្វឆ្លើយថា) គ្រឿងបរិភោគនេះបរិបូណ៌ដោយបរិវារ អ្នកបានគាត់តែងហើយ ពួកជនតែងទំពាស៊ី បរិភោគផឹកនូវគ្រឿងបរិភោគនោះ អ្នកស្គាល់ហើយនូវយើងថាជាអ្នកចិញ្ចឹមជីវិតដោយសារអ្នកដទៃឲ្យ សូមឲ្យមនុស្សច្រណែនបានន្ទូវដុំថ្មដែលបុគ្គលគប្បីទៅឈរដិត ។

(១៦៤) (មណ្ឌព្យកុមារ...) គ្រឿងភោជននេះ ខ្ញុំបានគាត់តែងបម្រុងពួកព្រាហ្មណ៍ នេះជាភោជនរបស់ខ្ញុំដែលដឿចំពោះសេចក្តីចំរើនរបស់ខ្លួន អ្នកប្លែកចៀសចេញអំពីទីនេះ អ្នកមកបិតនៅ កន្លែងនេះធ្វើអ្វី នែបុគ្គលថោកទាប បុគ្គលគាំងឆ្ងាយប្រហែលយើង មិនឲ្យភោជនដល់អ្នកទេ ។

(๑๖๕) ជលេ ច ឆិន្នេ វបន្តិ តីណិ

អន្ធមខេត្តេ ផលមាសីសមានា

ឯតាយ សច្ចាយ ឧទាហរិ ធានំ

អបេត្ថ អាភជយេ ឧក្កំសោយេ្យ ។

(๑๖๖) ខេត្តានំ មយ្ហំ វិទិតានំ លោកេ

យេសាហំ ពីជានំ បតិដ្ឋបេមិ

យេ ព្រាហ្មណា ជាតិមន្តូបបន្នា

តានីធ ខេត្តានំ សុបេសលានំ ។

(๑๖๗) ជាតិមនោ ច អតិមានិតា ច

លោភោ ច នោសោ ច មនោ ច មោហោ

ឯតេ អកុណា យេសុ ច សន្តិ សព្ពេ

តានីធ ខេត្តានំ អបេសលានំ ។

ជាតិមនោ ច អតិមានិតា ច

លោភោ ច នោសោ ច មនោ ច មោហោ

ឯតេ អកុណា យេសុ ន សន្តិ សព្ពេ

តានីធ ខេត្តានំ សុបេសលានំ ។

វិសតិនិបាត មាតង្គជាតក ទី ១

(១៦៥) (ព្រះមហាសត្វ...) ពួកអ្នកប្រាថ្នាផលស្រូវ រមែងព្រោះពូជក្នុងទីទួលឬទីទំនាប ទំនងទីដែលមិនមែនជាស្រែ អ្នកចូរឲ្យទានដោយសទ្ធាបែបនេះចុះ សូមអ្នកញុំាងទក្ខិណេយ្យបុគ្គលឲ្យត្រេកអរផង ។

(១៦៦) (មណ្ឌព្យកុមារ...) យើងព្រោះពូជទាំងឡាយក្នុងស្រែណា ស្រែទាំងនោះកុងលោក យើងស្គាល់ច្បាស់ ពួកព្រាហ្មណ៍ណា ជាអ្នកប្រកបដោយជាតិនឹងមន្ត ពួកព្រាហ្មណ៍ទាំងនោះ មានសីលជាទីស្រឡាញ់ដ៏ក្រៃលែង ដូចជាស្រែក្នុងលោកនេះ ។

(១៦៧) (មហាសត្វ...) សេចក្តីស្រវឹងព្រោះជាតិ ១ ភាពជាបុគ្គលមើលងាយគេ១ លោភៈ១ ទោសៈ១ សេចក្តីស្រវឹង ១ មោហៈ១ ទោសទាំងអស់នេះ មាននៅក្នុងពួកបុគ្គលណា បុគ្គលពួកនោះ មិនមែនជាអ្នកមានសីលជាទីស្រឡាញ់ដ៏ក្រៃលែង ដូចជាស្រែក្នុងលោកនេះឡើយ ។ សេចក្តីស្រវឹងព្រោះជាតិ ១ ភាពជាបុគ្គលមើលងាយគេ ១ លោភៈ ១ ទោសៈ ១ សេចក្តីស្រវឹង ១ មោហៈ ១ ទោសទាំងអស់នេះ មិនមានក្នុងពួកបុគ្គលណា បុគ្គលពួកនោះ ទើបឈ្មោះថាមានសីលជាទីស្រឡាញ់ដ៏ក្រៃលែង ដូចជាស្រែក្នុងលោកនេះ ។

(๑๖๘) ภิกฺขุ กตา ขุปเปตพฺพา จ
ขุปฺปญฺญายา ภชิตา กลฺยาณภิกฺขุนา
สมสฺสุ ธมฺมญฺจ วินญฺจ ธมฺมา
กเล กเถตฺวา กลยาย[๑] ปตฺตึ ฯ

(๑๖๙) ตีหิ ฉเฬเฉ ฉฬาสเน อยา ฉเฬเก ฉาฉสเน
ฉาตเวหิ ปฉยาสเน เย สนฺติ ปริกาสเน ฯ

(๑๗๐) สนฺติ ภิกฺขเว ภาเคยฺยา สนฺติ สงฺฆปริกฺขารา
อฏฺฐิเต ภิกฺขุสฺมึ ปกฺกามิ ปฺรหฺมณาน ขุทิภิกฺขุตา ฯ

(๑๗๑) อาวิลิตา ปิฏฺฐิโต ขุตฺตมฺปิ
ภาหุ ปสาเรตา อกมฺเนยฺยา
เสนาย อกฺกีย ยถา มตสฺส
เอวา เม สมึ ปุตฺตมาสา ฆาฺ ฯ

(๑๗๒) สมาคมา สมณสฺส ขุมฺภสฺส
ขิตฺตเจตา ปีสุณสาจเวาร
สงฺฆาเรเยฺย ปฺรมุญฺจ เกฬฺห
เสา เต สมึ ปุตฺตมาสา ฆาฺ ฯ

๑- ม. ฉลยาย ฯ

(១៦៨) (មណ្ឌព្យកុមារ...) (ឆ្នាំទ្វារពេនាក់) ឈ្មោះឧបដោតិយៈ១ ឈ្មោះឧបដ្ឋាយៈ១ ឈ្មោះភណ្ឌកុច្ឆិ ១ ទៅកន្លែណា អ្នកទាំងឡាយចូរវាយសម្លាប់នូវមនុស្សលាមកនេះ ហើយចាប់ត្រង់ក អូសទាញចេញទៅ ។

(១៦៩) (មហាសត្វ...) អ្នកណាដេរប្រទេចនូវឥសី អ្នកនោះឈ្មោះថាដឹកក្នុងដោយក្រចក ឈ្មោះថាទាំទិពាដែកដោយធ្មេញ ឈ្មោះថាព្យាយាមលេបភ្លើង ។

(១៧០) (អភិសម្ពុទ្ធគាថា) ឥសីឈ្មោះមាតង្គៈ ជាអ្នកមានសេចក្តីព្យាយាមទៀងទាត់ លុះពោលពាក្យនេះហើយក៏ចេញទៅឰដ៏អាកាសចំពោះមុខពួកព្រាហ្មណ៍កំពុងក្រមៃក្រមើល ។

(១៧១) (នាងទិដ្ឋមង្គលិកាពោលថា) កូឡ (របស់កូនអញ) រមួលទៅខាងក្រោយ ដើមដៃលាតចេញទៅមិនគួរដល់ការងារ ក្អែកទាំងឡាយសដូចជាបុគ្គលស្លាប់ អ្នកណាហ៊ាន ធ្វើកូនអញនេះ ឲ្យទៅជាយ៉ាងនេះ ។

(១៧២) (ពួកមាណពពោលថា) មានសមណៈ (មួយរូប) មកកន្លែនេះ មានប្រដាប់ស្លៀកពាក់អាក្រក់ លាមក ដូចជាបិសាចលើអាចម៍ដី ពាក់នូវកំណាត់សំពត់ ដែលគេចោលលើគំនរសម្រាមឰដ៏ក សមណៈនោះបានធ្វើនូវកូនរបស់នាងនេះ ឲ្យយ៉ាងនេះ ។

(๑๗๓) តាតមិ ធិសំ អតមា ភូរិបញ្ញោ
អង្គាឌ មេ ឃាណាក ឯតមត្ថំ
តង្គាធ តំ បដិតាវេមុ អក្ខយំ
អបេរ្ហ ដំ បុត្តំ លភេមុ ជីវិតំ ។

(๑๗๔) វេហាយសំ អតមា ភូរិបញ្ញោ
បថទ្ធុនោ បណ្ណរសេវ ចង្កោ
អបិចាបិ សោ បុរិមំ ធិសំ អតច្ឆ
សច្ចប្បដិញ្ញោ ឥសិ សាធុរូបោ ។

(๑๗๕) អាវេឡិតំ បិដ្ឋិតោ ឧត្តមង្គំ
ពាហុំ បសារេតំ អតម្មរេយ្យុំ
សេតានិ អក្ខីនិ យថា មតស្ស
តោ បេ ឥមំ បុត្តមតាសិ ឃំ ។

(๑๗๖) យក្ខា មាវេ សន្តិ មហានុភាវា
អន្ធាតតា ឥសយោ សាធុរូបា
តេ ទុដ្ឋចិត្តំ តរុបិតំ វិនិត្វា
យក្ខា ហិ តេ បុត្តមតាសុ ឃំ ។

(១៧៣) (នាឯ.ដ្ឋមគ្គលិកា .) សមណៈមានប្រាជ្ញាក្រាស់ ដូចផែនដីនោះ ទៅកន្លងសូចម្តេច ម្នាលមាណពចាំឯង្ឃាយ អ្នកចាំឯង្ឃាយចូរប្រាប់ នូវសេចក្តីនុ៎ះដល់ខ្ញុំ យើងនឹងទៅសួរមាគោសចំពោះសមណៈនោះ ធ្វើម្តេចហ្ន៎ យើងនឹងបានកូននោះ មានជីវិតរស់នៅ ។

(១៧៤) (ពួកមាណព...) សមណៈមានប្រាជ្ញាក្រាស់ដូចផែនដី បានទៅកន្លងអាកាស ដូចព្រះចន្ទកន្លងថ្ងៃ ១៥ កើត ដើរទៅតាមផ្លូវនៃអាកាស មួយទៀត សមណៈនោះជាឥសី មានការប្តេជ្ញាដ៏ខ្ជៀងខាត់ មានសភាពដ៏ល្អ បានទៅកាន់ទិសខាងកើតហើយ ។

(១៧៥) (នាឯ.ដ្ឋមគ្គលិកា...) ក្បាល (របស់កូនខ្ញុំ) រមួលទៅខាងក្រោយ ដើមដៃលាតចេញទៅ មិនគួរដល់ការងារ ក្អែកចាំឯង្ឃាយសដូចក្អែកបុគ្គលស្ងាប់ អ្នកណាហ្ន៎ ធ្វើកូនខ្ញុំនេះ ឲ្យទៅជាយ៉ាងនេះ ។

(១៧៦) (ព្រះមហាសត្វ...) ពួកយក្សមានអានុភាពច្រើន (មកដោយគិតថា) ពួកឥសីមានសភាពដ៏ល្អ មកហើយ (ក្នុងទីនេះ) ពួកយក្ខដឹងថា (កូនរបស់នាង) មានចិត្តប្រទូស្ត ក្រោធខឹង ហើយបានធ្វើនូវកូននាង ឲ្យយ៉ាងនេះ ។

(๑๗๗) យក្ខោ ច មេ បុត្តមកាសុ ឃរំ
ភុញ្ជាវមេ មា ភុង្ខោ ព្រហ្មចារី
តុម្ហេ ចាទេ សរណំ គតាស្មិ
អជ្ជាតតា បុត្តសោកេន តិក្ខុ ។

(๑๗๘) តទេវ ហិ ឯតរហិ ច មយ្ហំ
មនោបនោសោ ន មមត្ថំ កោចិ
បុត្តោ ច តេ វេទមទេន មត្តោ
អត្ថំ ន ជានាតិ អធិច្ច វេទេ ។

(๑๗๙) អជ្ជា មាវេ តិក្ខុ មុហុត្តកេន
សម្មុយ្ហតេវ បុរិសស្ស សញ្ញា
ឯកោបកាំ ទម ភូរិបញ្ញ
ន បណ្ឌិតា កោធពលា ភវន្តិ ។

(๑๘๐) ឥទញ្ច មយ្ហំ ខុត្តិដ្ឋបិណ្ឌំ
តវ មណ្ឌព្យោ កុញ្ជតុ អប្បបញ្ញោ
យក្ខោ ច តេ បុត្តំ ន វិហេឋយេយ្យុំ
បុត្តោ ច តេ ហោសិតំ សោ អរោគោ ។

(๑๗๗) (នាងទិដ្ឋមង្គលិកា...) បើពួកយក្ខបានធ្វើកូនរបស់ខ្ញុំ ឲ្យយ៉ាងនេះហើយ សូមលោកជាអ្នកប្រព្រឹត្តធម៌ដ៏ប្រសើរ កុំខឹងចំពោះខ្ញុំ នាងខ្ញុំជាស្រីសូមដល់ នូវឋានៈរបស់លោកជាទីពឹងបពិត្រកិក្កិ ខ្ញុំមកដោយសេចក្តីសោកចំពោះកូន ។

(๑๗๘) (ព្រះមហាសត្វ..) កាលនោះក៏ដោយ ឥឡូវនេះក៏ដោយ យើងមិនមានការប្រទូស្តក្នុងចិត្តតិចតួចទេ តែកូនរបស់នាងជាអ្នកស្រវឹង ដោយសេចក្តីស្រវឹងក្នុងវេទ រៀនវេទហើយមិនស្គាល់សេចក្តីចំរើន ។

(๑๗๙) (នាងទិដ្ឋមង្គលិកា...) បពិត្រកិក្កិ សញ្ញារបស់បុរសរមែងភ្លេចភ្លាំង ដោយមួយរំពេចជាប្រាកដ បពិត្រលោកមានប្រាជ្ញាក្រាស់ដូចផែនដី សូមលោកអត់ទ្រាំទោសកំហុសម្តងចុះ អ្នកប្រាជ្ញតាំងច្បាយ រមែងមិនមានក្រោធជាកំភ្លាំង ។

(๑๘๐) (ព្រះមហាសត្វ...) ចូរឲ្យមណ្ឌព្យកុមារ ដែលជាបុគ្គលមានប្រាជ្ញាតិច ជាបុត្តរបស់នាង បរិភោគនូវដុំបាយ ដែលយើងឈរហើយបានមកនេះ ចំណែកខាងពួកយក្ខនឹងលែងបៀតបៀននូវកូនរបស់នាង តាំងកូនរបស់នាងនោះ នឹងទៅជាបុគ្គលមិនមានរោគ ។

វិសេតិនិបាតេ បឋមំ មាតង្គជាតកំ

(๑๘๑) បណ្ណាឃ្យ ពាណោសិ បវិត្តបញ្ញោ

យោ បុញ្ញខេត្តានមកោវិទោសិ

មហាក្កសាវេសុ ឧទាសិ ទានំ

កិលិដ្ឋកម្មេសុ អសញ្ញតេសុ ។

ជជា ច កោសា អជិនា ជិវ្ហា

ជវូទចាទំវ មុខំ បរុឌ្ហំ

បជំ ឥមំ បស្សថ ធុម្មរូបំ

ន ជជាជិនំ តាយតេ អប្បបញ្ញំ ។

យេសំ ភតោ ច នោសោ ច អវិជ្ជា ច វិភជិតា

ទីឃាសភ អរហាឡ្ហោ តេសុ ទិន្នំ មហប្ផលន្តិ ។

(๑๘๒) ឧបមាឃ្ន មនំ មេជ្ឈា មាតង្គស្មិំ យសស្សិនេ

សចាវិសជ្ជោ ឧច្ចិដ្ឋោ មេជ្ឈញ្ចំ តនា អហូតិ ។

មាតង្គជាតកំ បឋមំ ។

(๑๗๑) (នាងទិដ្ឋមង្គលិកា...) ម្នាលមណ្ឌព្យៈ អ្នកជាបុគ្គលពាល មានប្រាជ្ញាស្តួចស្តើង អ្នកជាបុគ្គលមិនស្គាល់ នូវបុព្វាក្ខេតទាំងឡាយ អ្នកឲ្យទានចំពោះតែពួកជន ដែលមានទឹកចត់គឺកិលេសដ៏ច្រើន មានអំពើដ៏សៅហ្មង ជាអ្នកមិនសង្រួម ។ (ពួកជនខ្លះ) ប្លងសក់ ស្លៀកនូវសម្លៀកខ្លាឃ្មុំ មានមុខគ្រុបគ្រុល (ដោយពុកមាត់ពុកចង្កា) ដូចរណ្តៅទឹកដ៏ចាស់ អ្នកទាំងឡាយ ចូរមើលពួកសត្វដែលមានសភាពអាក្រក់នេះចុះ ដ្បិតក្នងសក់នឹងសម្លៀកខ្លាឃ្មុំ ការពារនូវបុគ្គល ដែលមានប្រាជ្ញាតិច មិនបានទេ ។ ពួកបុគ្គលណា លះបង់ពាក្យទោស: នឹងអវិជ្ជា ពួកបុគ្គលនោះ ឈ្មោះថា ជាអរហន្តខីណាស្រព ទានដែលបុគ្គលឲ្យចំពោះពួកបុគ្គលទាំងនោះ ទើបជាទានមានផលច្រើន ។

(๑๗๒) (អតិសម្ពុទ្ធគាថា) ស្តេចកង់ដែនមេជ្ឈ: បៀតបៀននូវចិត្តរបស់មាតង្គតាបស ជាអ្នកមានយស ស្តេចកង់ដែនមេជ្ឈ: ព្រមទាំងបរិស័ទក៏ដាច់សូន្យ ដែនឈ្មោះមេជ្ឈ:ក៏ទៅជាព្រៃក្នុងកាលនោះ ។

ចប់ មាតង្គជាតក ទី ๑ ។

បិត្តសមជាតកំ

(๑๘๓) សព្វំ ឧភយំ សជលំ សុចិឡ្ហំ
ន ភក្ខ្មា តាទិនេ មោឃមត្ថិ
បសន្នមិ សម្ពុទ្ធេ មហានុភាវេ
សភក្ខ្មា បុញ្ញផលូបបន្នំ ។
សព្វំ ឧភយំ សជលំ សុចិឡ្ហំ
ន ភក្ខ្មា តាទិនេ មោឃមត្ថិ
ភក្ខ្មំ ចិត្តសម្បទំ ឱឡារេ
ឥទ្ធោ មនោ តស្ស យថាបិ មយ្ហំ ។

(๑๘๔) សព្វំ ឧភយំ សជលំ សុចិឡ្ហំ
ន ភក្ខ្មា តាទិនេ មោឃមត្ថិ
ចិត្តំបិ ជានាហិ តថេវ ឯតំ
ឥទ្ធោ មនោ តស្ស យថាបិ តុយ្ហំ ។

(๑๘๕) ភវំ នុ ចិត្តោ សុតមញ្ញតោ តេ
ឧទាហុ តេ កោចិ ឥធនក្ខាតា
តាថា សុតីតា ន មមត្ថិ ភក្ខ្មា
ឧទាមិ តេ តាមរំ សតញ្ហ ។

បិត្តសម្ភវជាតក

(๑๘๓) (ព្រះរាជាត្រាស់ថា) សេចក្តីខ្វល់ខ្វាយដោយការងារទាំងអស់ ដែលនរជនទាំងឡាយសន្សំហើយដោយប្រពៃ រមែងប្រកបដោយផល មិនមែនឥតអំពើទេ ខ្ញុំឃើញសម្ភវបណ្ឌិត មានអានុភាពច្រើន ជាអ្នកបរិបូណ៌ដោយផលនៃបុណ្យដោយការងាររបស់ខ្លួន ។ សេចក្តីខ្វល់ខ្វាយដោយការងារទាំងអស់ ដែលនរជនទាំងឡាយសន្សំហើយដោយប្រពៃ រមែងប្រកបដោយផល មិនមែនឥតអំពើទេ ចិត្តរបស់បណ្ឌិតឈ្មោះចិត្តៈនោះសម្រេច ដូចចិត្តអាត្មាអញដែរឬហ្ន៎ ។

(๑๘๔) (ទារកប្រៀនទូលថា) សេចក្តីខ្វល់ខ្វាយដោយការងារទាំងអស់ ដែលនរជនទាំងឡាយសន្សំហើយ ដោយប្រពៃ រមែងប្រកបដោយផល មិនមែនឥតអំពើទេ បពិត្រព្រះសម្មតិទេព សូមព្រះអង្គទ្រង់ជ្រាប នូវបណ្ឌិតឈ្មោះចិត្តៈនោះ មានចិត្តសម្រេច ដូចព្រះរាជហឫទ័យព្រះអង្គដែរ ។

(๑๘๕) (ព្រះរាជា...) (សំដីនេះ) អ្នកបានឮមក (អំពីសំណាក់) បណ្ឌិតឈ្មោះចិត្តៈដ៏បំរើនែឬ ឬជនណាមួយប្រាប់សេចក្តីនុ៎ះដល់អ្នក គាថា (នេះ) អ្នកប្រៀនពីពេះហើយ ខ្ញុំមិនមានសេចក្តីសង្ស័យទេ ខ្ញុំឲ្យស្រុកស្រួយមួយរយ ដល់អ្នក ។

[๑๘๖] ๘ ថាមាំ តំត្តោ សុគមញ្ញតោ មេ
๙សិ ๘ មេ ฝតមត្តំ អសំសិ
តត្ថាន រញ្ញោ បដិគាយេ គាថំ
អបិ ន្វតេវរំ អត្តមនោ ន ទេយ្យ ។
[๑๘๗] យោជេន្តុ មេ[๑] ภ๘រថ សុកតេ ចិត្តសំភវេ
ករុំ ជាតានំ ๓๒๙ តីវេយ្យំ បដិមុញ្ច๙ ។
អាហញ្ញវេ កេរិមុទិង្គសង្ខា[๒]
សីឃាឌំ យានានំ ច យោ๘យន្តុ
អជ្ជេវាហំ អស្សមេតំ ภមិស្សំ
យត្ថេវ ន ភក្ខិស្សមិសី ឌិសិន្ទុំ ។
[๑๘๘] សុលទ្ធលាភោ វត មេ អហោសិ
គាថា សុតីតា បរិសាយ មជ្ឈេ
សោហំ ๙សឹ សីលវតូបបន្នំ
ទិស្វា បតីតោ សុមនោហមស្មិ ។
[๑๘๙] អាសនំ ឧទកំ បជ្ជំ បដិក្កណ្ហាតុ នោ ภវំ
អក្ខេ ภ๘ន្តុ បុច្ឆាម អក្ខាំ ភាសតុ នោ ภវំ ។

---

๑ ឧ. យោជេត្តុ វេ ។ ម. យោជិត្តុ វេ ។ ๒ ឧ. អាហញ្ញាវុ ភេរិមុទិង្គសង្ខេ ។ ម. អាហញ្ញត្តុ ភេរិមុទិង្គសង្ខេ ។

(១៨៦) (តាវក...) ខ្ញុំព្រះអង្គ មិនបានឮ (អំពីសំណាក់) បណ្ឌិត ឈ្មោះចិត្តៈទេ តែឥសី (មួយរូប) បានប្រាប់នូវសេចក្តីនេះ ដល់ខ្ញុំព្រះអង្គថា អ្នកចូរទៅប្រៀនប្រដៅនូវតាវតឹង្សព្រះពជា ក្រែងលោស្តេចសព្វព្រះពជហប្តទ័យ នឹងប្រោសប្រទាន នូវរបស់ដ៏ប្រសើរដល់អ្នក ។

(១៨៧) (ព្រះពជា...) អ្នកចាំឆ្លាយចូរទឹមនូវពាជរថចាំឆ្លាយ ដែលធ្លាប់ឆ្លាស់ល្អ គ្រឿងប្រដាប់ដ៏ពិចិត្ត ចូរបង់នូវខ្សែដង្គន់ ពាក់នូវគ្រឿងប្រដាប់កនៃដំរីចាំឆ្លាយ ។ អ្នកចាំឆ្លាយ ចូរពាយស្គរនឹងសំគោរដ្ឋុំនូវសង្ខផង ចូរទឹមនូវយានចាំឆ្លាយដ៏លឿនៗផង ថ្ងៃនេះឯង អញនឹងទៅមើលឥសី ដែលគង់ក្នុងអាស្រមណា អញនឹងទៅកាន់អាស្រមនោះ ។

(១៨៨) ឧហ្ន៎ អាត្មាអញ មានលាភល្អណាស់តើ គាថាដែលអាត្មាអញប្រៀនពីរោះហើយ ក្នុងកណ្តាលបរិស័ទ អាត្មាអញបានឃើញ នូវឥសី ដ៏បរិបូណ៌ដោយសីលនឹងវត្ត ហើយក៏ត្រេកអរពេកក្រៃ ។

